ក្រសួងមុខងារសាធារណៈ

MINISTRY OF CIVIL SERVICE




# សមិទ្ធផលការងារក្រសួងមុខងារសាធារណៈ ឆ្នាំ ២០២៣

# មាតិកា

លេខទំព័រ


**ក. សេចក្តីផ្តើម** .......... ០១

**ខ. វឌ្ឍនភាពការងារ** .......... ០១

**ខ.១. ការគ្រប់គ្រង និងអភិវឌ្ឍមុខងារសាធារណៈ** .......... ០១

**ខ.១.១.ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល** .......... ០១

ខ.១.១.១. ការងារគ្រប់គ្រងក្របខណ្ឌ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា .......... ០១

ខ.១.១.២. ការងារបៀវត្ស .......... ០២

ខ.១.១.៣. ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលមន្ត្រីរាជការស៊ីវិល .......... ០៣

ខ.១.១.៤. កិច្ចការវិមជ្ឈការ និងវិសហមជ្ឈការ .......... ០៤

ខ.១.១.៥. កិច្ចការយេនឌ័រ .......... ០៥

**ខ.១.២. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ** .......... ០៧

**ខ.១.៣. ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធឌីជីថល** .......... ០៩

**ខ.១.៤. កិច្ចការគោលនយោបាយមុខងារសាធារណៈ** .......... ១១

**ខ.១.៥. កិច្ចការអធិការកិច្ចវិស័យមុខងារសាធារណៈ** .......... ១៣

**ខ.២. ការកែទម្រង់រដ្ឋបាលសាធារណៈ** .......... ១៤

**ខ.២.១. ការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ** .......... ១៤

វិធានការគន្លឹះទី១ - ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី .......... ១៤

វិធានការគន្លឹះទី២ - ការលើកកម្ពស់ប្រសិទ្ធភាពការងារ .......... ១៥

វិធានការគន្លឹះទី៣ - ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម .......... ១៥

**ខ.២.២. ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ** .......... ១៥

ខ.២.២.១. ការងារបរិវត្តកម្ម និងនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ .......... ១៥

ខ.២.២.២. ការងារលើកកម្ពស់ឧត្តមភាពសេវាសាធារណៈ .......... ១៥

ខ.២.២.៣. ការងារគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស .......... ១៦

ខ.២.២.៤. ការងារកសាងសមត្ថភាពមន្ត្រី .......... ១៦

ខ.២.២.៥. ការរៀបចំនិងធ្វើបច្ចុប្បន្នភាពកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ .......... ១៦

ខ.២.២.៦. ការរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ការកែទម្រង់រដ្ឋបាលសាធារណៈ .......... ១៦

ខ.២.២.៧. ការងារសម្របសម្រួលការងារកែទម្រង់អន្តរវិស័យ .......... ១៧

ខ.២.២.៨. ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ .......... ១៨

**ខ.៣. ការគាំទ្រកិច្ចការមុខងារសាធារណៈ** .......... ១៨

**ខ.៤. ការងារសវនកម្មផ្ទៃក្នុង** .......... ២៤

**ខ.៥. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត** .......... ២៥

**គ. បញ្ហាប្រឈម** .......... ២៥

**ឃ. ទិសដៅការងារបន្ត** .......... ២៦

**ង. សេចក្តីសន្និដ្ឋាន** .......... ២៧

# បញ្ជីតារាង

តារាង១.  ការបង្វែរប្រាក់បៀវត្សដែលបានបើកលើសនៅក្នុងឆ្នាំ២០២៣ នៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត .. ៣
តារាង២.  តារាងផ្លាស់ប្តូរស្ថានភាពរដ្ឋបាលមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ..................................... ៤
តារាង៣.  តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ជាស្ត្រីដែលមានមុខតំណែងគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤ ........................................................................................................... ៦
តារាង៤. ដំឡើងបៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ ............................................................. ១១
តារាង៥.  ស្ថានភាពរដ្ឋបាលមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ ................................................ ១៩
តារាង៦.  លទ្ធផលនៃការផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្តាញសង្គម ................................................. ២១
តារាង៧.  លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបានក្នុងឆ្នាំ២០២៣....................................................... ២២

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ក. កម្រងរូបភាព សកម្មភាពថ្នាក់ដឹកនាំ ........................................................................ ២៨

# របាយការណ៍
# សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣
# និងលើកទិសដៅឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ

## ក. សេចក្តីផ្តើម

ក្រោមម្លប់នៃសន្តិភាពនិងស្ថេរភាពសង្គម រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយផ្តោតលើអាទិភាពគន្លឹះ ៥គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**។

គោលដៅយុទ្ធសាស្ត្រដែលពាក់ព័ន្ធផ្ទាល់នឹងវិស័យមុខងារសាធារណៈគឺ ការបន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ស្នូលនៃយុទ្ធសាស្ត្រគឺ **ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច** ដែលនៅក្នុងនោះ មុំ៣ ក្នុងចំណោមមុំទាំង៥ដែលក្រសួងមុខងារសាធារណៈ ត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្តដោយផ្ទាល់គឺ (១)**ការពង្រឹង និងការកែទម្រង់ស្ថាប័ន** (២)**ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ**និង(៣)**ការលើកកម្ពស់និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ**។

ក្រសួងមុខងារសាធារណៈត្រូវបានប្រគល់ភារកិច្ចក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចការអនុវត្តវិធានការគន្លឹះសំខាន់៣ ក្នុងចំណោមវិធានការគន្លឹះទាំង៥ គឺ (១)**ការដាក់ឲ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព** (២)**ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** និង(៣)**ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព**។

ដោយទទួលបាននូវការប្រគល់ភារកិច្ចដ៏មានសារៈសំខាន់ និងប្រកបដោយកិត្តិយសខាងលើនេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈបានប្តេជ្ញាចិត្ត ខិតខំបំពេញភារកិច្ច ហើយទទួលបានវឌ្ឍនភាពការងារ និងកំណត់ទិសដៅអនុវត្តបន្ត របស់ខ្លួន។ នៅក្នុងរយៈពេល១ឆ្នាំ នៃឆ្នាំ២០២៣ នេះ ក្រសួងមុខងារសាធារណៈ សម្រេចបានសមិទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម៖

## ខ. វឌ្ឍនភាពការងារ

### ខ.១. ការគ្រប់គ្រង និងអភិវឌ្ឍមុខងារសាធារណៈ

#### ខ.១.១.ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

##### ខ.១.១.១. ការងារគ្រប់គ្រងក្របខណ្ឌ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា

សម្រាប់កិច្ចការងារនេះ ក្រសួងមុខងារសាធារណៈ បានសម្រេចលទ្ធផលដូចខាងក្រោម៖

- ផែនការប្រើប្រាស់ក្របខណ្ឌឆ្នាំ២០២៤ ត្រូវបាននិងកំពុងពិនិត្យឡើងវិញ។ ដោយឡែកមន្ត្រីជាប់កិច្ចសន្យា (ចំនួន១៧,៤៥២កន្លែង) ឆ្មាំទំនប់ប្រព័ន្ធធារាសាស្ត្រ (ចំនួន២៥០កន្លែង) គ្រូពុទ្ធិកសិក្សា (ចំនួន១,៤៤៦កន្លែង) គណៈគ្រប់គ្រងសាលាពុទ្ធិកសិក្សា (ចំនួន៣៥២កន្លែង) គ្រូបង្រៀនប្រភេទផ្សេងទៀត (ចំនួន២៦,៩៧០កន្លែង) ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់
- នៅក្នុងឆ្នាំ២០២៣ រាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យជ្រើសរើសក្របខណ្ឌថ្មីចំនួន ៣,៨៦៣កន្លែង។ ក្នុងនោះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងត្រូវបានរៀបចំប្រឡងជ្រើសរើស

- សម្រាប់ក្របខណ្ឌក្រសួងសុខាភិបាល ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន២០០កន្លែង និងមន្ត្រីជាប់កិច្ចសន្យាចំនួន៣០០កន្លែង តាមរយៈការប្រឡងប្រជែងឱ្យចូលបម្រើការងារនៅ ***មន្ទីរពេទ្យតេជោសន្តិភាព***
- ការជ្រើសរើសក្របខណ្ឌតាមរយៈការប្រឡងឱ្យចូលបម្រើការងារក្នុងក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០២៣ និងបានរៀបចំការប្រឡង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយអនុវត្តតាមនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល រួមមាន៖ (១) ការជ្រើសរើសមន្ត្រីកសិកម្មឃុំ/សង្កាត់ចំនួន២៥០កន្លែង (២)ជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ចំនួន១០០កន្លែង (៣)អង្គភាពប្រឆាំងអំពើពុករលួយ ជ្រើសរើសមន្ត្រីចំនួន៣៣កន្លែង (៤)ក្រសួងសាធារណការ និងដឹកជញ្ជូន ជ្រើសរើសមន្ត្រីចំនួន៩៩កន្លែង និង (៥)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន៥២កន្លែង
- ផ្តល់ទិដ្ឋាការលើការបញ្ចូលក្របខណ្ឌសរុបចំនួន៦,៣០០នាក់ (ស្រ្តី៣,៥៤៧នាក់) តាមរយៈ (១)ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០២៣ ចំនួន៥,៥២២នាក់ (ស្ត្រី៣,១៦៥នាក់) ក្នុងនោះថ្នាក់ក្រោមជាតិចំនួន១២៥នាក់ (ស្ត្រី៤៧នាក់) និង (២)ករណីពិសេសចំនួន៩១០នាក់ (ស្ត្រី៤១០នាក់)
- ក្នុងឆ្នាំ ២០២៣ ក្រសួង-ស្ថាប័នរដ្ឋចំនួន ៣៩ មានជនមានពិការភាពចូលបម្រើការងារចំនួន ៣ ៧៧៦នាក់ (២.០៥% នៃមន្ត្រីចូលបម្រើការងារសរុប) ក្នុងនោះស្ត្រីមានពិការភាពចំនួន ៨៦៩នាក់។ ជនមានពិការភាពកម្រិតធ្ងន់ចំនួន ២ ៣៥១នាក់ (ប្រភព៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)
- នៅក្នុងឆ្នាំ២០២៣ មានមន្ត្រីរាជការចូលនិវត្តន៍សរុបចំនួន២,៣៧៣នាក់ ក្នុងនោះរួមមាន (១)មន្ត្រីលុបឈ្មោះ ចំនួន៧១៧នាក់ (២)បាត់បង់សម្បទាវិជ្ជាជីវៈចំនួន៥២នាក់ និង (៣)ចូលនិវត្តន៍ចំនួន១,៦០៤នាក់
- នៅក្នុងឆ្នាំ២០២៣ រាជរដ្ឋាភិបាល បានសម្រេចប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាសរុបចំនួន៤៦,០២៣កន្លែង ក្នុងនោះ (១)មន្ត្រីជាប់កិច្ចសន្យាចំនួន១៧,០២៤កន្លែង (២)ឆ្មាំទំនប់ចំនួន២៥០កន្លែង (៣)គ្រូពុទ្ធិកសិក្សាចំនួន ១,៤៧២កន្លែង (៤)គណៈគ្រប់គ្រងសាលាពុទ្ធិកសិក្សាចំនួន៣៥២កន្លែង និងគ្រូបង្រៀនជាប់កិច្ចសន្យាប្រភេទផ្សេងទៀតចំនួន២៦,៩៣៥កន្លែង
- ព័ត៌មានទីតាំងសលាកប័ត្រមន្ត្រីរាជការចំនួន ៧,៥២៧នាក់ ត្រូវបានបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់បណ្ណសារដ្ឋាន
- ស្កេនសលាកប័ត្រព័ត៌មានមន្ត្រីរាជការចំនួន ១,០២៥នាក់ ស្មើនឹង ១៤,៨៨២សន្លឹក
- បញ្ចូលទិន្នន័យជាឯកសាររូបភាពក្នុងប្រព័ន្ធចំនួន ១,០២៨នាក់ ស្មើនឹង ១៥,០១៨សន្លឹក

**ខ.១.១.២. ការងារបៀវត្ស**

ស្ថានភាពបៀវត្សរបស់មន្ត្រីរាជការស៊ីវិលមានដូចខាងក្រោម៖

- ស្ថិតិមន្ត្រីនៅក្នុងតារាងទូទាត់បៀវត្សប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ មានចំនួនសរុប ២៣០,៩១៥នាក់ (ស្ត្រី ៩៥,៩២៦នាក់) នៅថ្នាក់កណ្តាល ៥៣,៣០០នាក់ ស្មើនឹង ២៣.០៨% (ស្ត្រី ១៥,៦២០នាក់) និងថ្នាក់រាជធានី ខេត្ត ១៧៧,៦១៥នាក់ ស្មើនឹង ៧៦.៩២% (ស្ត្រី ៨០,៣០៦នាក់) ក្នុងនោះរួមមាន៖
    - ចំនួនមន្ត្រីរាជការស៊ីវិលសរុប ២២២,០៩១នាក់ ស្មើនឹង១០០% (ស្ត្រី ៩៤,៤៦៤នាក់) នៅថ្នាក់កណ្តាល ៤៤,៥៥១នាក់ ស្មើនឹង ២០.០៦% (ស្ត្រី ១៤,១៩៨នាក់) និងថ្នាក់រាជធានី ខេត្ត ១៧៧,៥៤០នាក់ ស្មើនឹង ៧៩.៩៤% (ស្ត្រី ៨០,២៦៦នាក់)
        - ក្របខណ្ឌ "**ក**" នៅថ្នាក់កណ្តាល ៣២,២១៨នាក់ ស្មើនឹង ៤៥.០២% (ស្ត្រី ៩,១១៥នាក់) និងថ្នាក់រាជធានី ខេត្ត ៣៩,៣៤១នាក់ ស្មើនឹង ៥៤.៩៨% (ស្ត្រី ១២,៦៨៧នាក់)

- ក្របខណ្ឌ "**ខ**" នៅថ្នាក់កណ្ដាល ៨,៨៣២ នាក់ ស្មើនឹង ១១.៩៥% (ស្ត្រី ៣,៧៧៥នាក់) និងថ្នាក់រាជធានី ខេត្ត ៦៦,៩៥៨នាក់ ស្មើនឹង ៨៨.០៥% (ស្ត្រី ២៩,៦៩៥នាក់)
- ក្របខណ្ឌ "**គ**" នៅថ្នាក់កណ្ដាល ៣,៥០១នាក់ ស្មើនឹង ៦.១៧% (ស្ត្រី ១,៣០៨នាក់) និងថ្នាក់រាជធានី ខេត្ត ៧១,២៤១នាក់ ស្មើនឹង ៩៣.៨៣% (ស្ត្រី ៣៧,៨៨៥នាក់)

- មន្ត្រីប្រភេទផ្សេងៗ (មន្ត្រីនយោបាយ ទីប្រឹក្សា ជំនួយការ...។ល។) នៅថ្នាក់កណ្ដាលមានចំនួន ៨,៧៤៩នាក់ ស្មើនឹង ៩៩.៥២% (ស្ត្រី ១,៤២២នាក់) និងថ្នាក់រាជធានី ខេត្ត មានចំនួន៧៥នាក់ ស្មើនឹង ០.៤៨% (ស្ត្រី ៤០នាក់)

- ជាទៀងទាត់ បោះពុម្ពតារាងទូទាត់បៀវត្ស និងអាណត្តិបើកប្រាក់សរុបចំនួន ៦៩៦ អង្គភាព ក្នុងនោះ ក្រសួង ស្ថាប័នថ្នាក់កណ្ដាលចំនួន៣៩៦អង្គភាព និងរាជធានី ខេត្តចំនួន៣០០ មានដូចខាងក្រោម៖
  - កែតម្រូវស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធព័ត៌មានវិទ្យាចំនួន២៤០,៥០២ករណី ក្នុងនោះថ្នាក់រាជធានីខេត្តចំនួន១៧៦,៧៧៤ករណី
  - ប្រើប្រាស់ឥណទានបៀវត្សចំនួន៥,០២៥,១៧២,៤៥៤,៣២៦រៀល ក្នុងនោះថ្នាក់រាជធានី ខេត្តចំនួន ៣,៧៤០,៥១៥,៥៤០,១៨៧រៀល
  - ស្នើឱ្យក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត បង្វែរប្រាក់បៀវត្សដែលបានបើកលើសនៅក្នុងឆ្នាំ ២០២៣ ដូចខាងក្រោម៖

**តារាង១. ការបង្វែរប្រាក់បៀវត្សដែលបានបើកលើសនៅក្នុងឆ្នាំ២០២៣ នៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត**

| បរិយាយ | ចំនួនសរុប | បានបង្វែរចូលថវិកាវិញ | នៅសល់ |
|---|---|---|---|
| ថ្នាក់កណ្ដាល | ៣,៧៩៩,១៣៩,០៤៨រៀល | ៥៨,៩៦២,៧៥០រៀល | ៣,៧៤០,១៧៦,២៩៨រៀល |
| ថ្នាក់រាជធានី ខេត្ត | ៩,៦៦៨,៣១៦,១៦៦រៀល | ៣,៩៥៨,៤៥៥,៧៩៦រៀល | ៥,៧០៩,៨៦០,៣៧០រៀល |
| **សរុប** | **១៣,៤៦៧,៤៥៥,២១៤រៀល** | **៤,០១៧,៤១៨,៥៤៦រៀល** | **៩,៤៥០,០៣៦,៦៦៨រៀល** |

- សម្របសម្រួលធ្វើសមាហរណកម្ម និងដំឡើងរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនឱ្យបានដល់កម្រិតអប្បបរមាចំនួន៨២៥០០០រៀល ដោយចាប់ផ្ដើមអនុវត្តពីខែមេសា ឆ្នាំ២០២៤

**ខ.១.១.៣.** ការផ្លាស់ប្ដូរស្ថានភាពរដ្ឋបាលមន្ត្រីរាជការស៊ីវិល

ការផ្លាស់ប្ដូរស្ថានភាពរដ្ឋបាលមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំដូចខាងក្រោម៖

- ត្រួតពិនិត្យផ្នែករដ្ឋបាលលើសំណើសុំរបស់ក្រសួង ស្ថាប័ន ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល និងផ្ដល់ទិដ្ឋាការជូនក្រសួង ស្ថាប័ន ដូចតារាង២
- ពិនិត្យ និងផ្ដល់អត្តលេខមន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មីចំនួន៦,៤៩០នាក់ (ស្ត្រី ៣,៤២៥នាក់)
- បោះពុម្ពសលាក័ត្រមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ដល់អាយុកំណត់ចំនួន១,៥២៤នាក់ (ស្ត្រី ៦០៧នាក់) និងមុនអាយុកំណត់១៣៤នាក់ (ស្ត្រី ៥៧នាក់)
- រៀបចំរបបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ចំនួន៨០៥នាក់ (ស្ត្រី ៣៩៧នាក់)
- បោះពុម្ពអត្តសញ្ញាប័ណ្ណមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិចំនួន១៩,៨៦៣នាក់ និងថ្នាក់ក្រោមជាតិចំនួន ១,៧៣៨នាក់។

តារាង២. តារាងផ្លាស់ប្តូរស្ថានភាពរដ្ឋបាលមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន

| លរ | បរិយាយ | សំណើសុំការសម្រេចពីសម្តេចនាយករដ្ឋមន្ត្រី | | ផ្តល់ទិដ្ឋាការជូនក្រសួងស្ថាប័ន | |
|---|---|---|---|---|---|
| | | សរុប(នាក់) | ស្ត្រី(នាក់) | សរុប(នាក់) | ស្ត្រី(នាក់) |
| ១ | តាំងស៊ប់ | ២,៩៩៤ | ១,២៧៥ | ១,៤៦៩ | ១,០២៩ |
| ២ | ដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ | ៩,៧៨០ | ២,២២៩ | ៣២,៦៣៤ | ១៤,៦៦៤ |
| ៣ | ដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមសញ្ញាបត្រ | ១,៦៦៣ | ៤០២ | ៦,៨៩២ | ៣,១៧៤ |
| ៤ | ផ្ទេរក្របខណ្ឌ | ២៨ | ៣ | ៦០០ | ១៤៩ |
| ៥ | តែងតាំង | ២៩៨ | ៤៤ | ៣,៣២០ | ១,០៧០ |
| ៦ | រៀបប្រាក់បំណាច់មុខងារ | ០ | ០ | ៨១២ | ២០១ |
| ៧ | បញ្ចប់មុខតំណែង | ១០ | ២ | ០ | ០ |
| ៨ | ស្ថិតនៅក្រៅក្របខណ្ឌដើម | ០ | ០ | ៣០ | ៨ |
| ៩ | ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ២ | ១ | ០ | ០ |
| ១០ | ចូលបម្រើការងារជាថ្មី | ១ | ០ | ១ | ១ |
| ១១ | ចូលនិវត្តន៍តាមកាលកំណត់ | ៣៦៦ | ៦៣ | ១,០១១ | ៤៥៣ |
| ១២ | ចូលនិវត្តន៍មុនកាលកំណត់ | ២៤ | ៦ | ១៧៣ | ៨៥ |
| **សរុប** | | **១៥,១៦៦** | **៤០២៥** | **៤៦,៩៤២** | **២០,៨៣៤** |

### ខ.១.១.៤. កិច្ចការវិមជ្ឈការ និងវិសហមជ្ឈការ

សម្រាប់កិច្ចការវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងមុខងារសាធារណៈ បានចូលរួមដូចខាងក្រោម៖

- ក្រុមការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងមុខងារសាធារណៈ ធ្វើជាគ្រូឧទ្ទេសសម្រាប់ការបណ្តុះបណ្តាលគោលការណ៍ បែបបទ និងនីតិវិធី អនុវត្តមុខងារអប់រំ យុវជន និងកីឡា ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅ៦តំបន់ ដែលបានរៀបចំនៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តបាត់ដំបង និងរាជធានីភ្នំពេញ
- ចងក្រងទិន្នន័យបុគ្គលិកអប់រំដែលត្រូវសមាហរណកម្មទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ សរុបចំនួន៥៩,២០៨នាក់។ ក្នុងនោះបានចេញដីកាផ្ទេររួចចំនួន៥៧,៧៤០នាក់
- កិច្ចប្រជុំពិភាក្សាលើ៖

  (១) ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

  (២) ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការត្រួតពិនិត្យស្ថានភាពបុគ្គលិកសុខាភិបាលថ្នាក់ក្រោមជាតិ និង

  (៣) ផ្តល់ធាតុចូលសម្រាប់ការកសាងឯកសារទស្សនទាន ការធ្វើបច្ចុប្បន្នភាពវិស័យអប់រំ និង វិស័យសុខាភិបាល
- កសាងអនុក្រឹត្យស្តីពីការកំណត់មុខដំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខដំណែងនានា ក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ចំនួន ៣រូប ចូលរួមក្នុងក្រុមការងារអន្តរក្រសួង ចុះសិក្សា និងវាយតម្លៃលើការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តកំពតមានចំនួន ៤គោលដៅ និងបានចូលរួមការរៀបចំនូវសេចក្តីព្រាងរបាយការណ៍វាយតម្លៃលើការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងកិច្ចប្រជុំបានចំនួន២លើក និងសិក្ខាសាលាចំនួន១លើក

- សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅលេខាធិការដ្ឋាន គ.ជ.អ.ប នៃក្រសួងមហាផ្ទៃ
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងមុខងារសាធារណៈ។

**ខ.១.១.៥.កិច្ចការយេនឌ័រ**

ក្រុមការងារយេនឌ័រ របស់ក្រសួងមុខងារសាធារណៈ បានសម្របសម្រួលសម្រេចការងារដូចខាងក្រោម៖

- ចូលរួមជាមួយប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្រ្តីក្នុងគោលបំណង៖

  (១) ប្រមូលព័ត៌មាន ទិន្នន័យ សមិទ្ធផលនានា ដែលអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ក្រោមជាតិ និងមន្ទីរ/អង្គភាពពាក់ព័ន្ធសម្រេចបានក្នុងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខុមាលភាពស្រ្តីក្នុងការអនុវត្តច្បាប់ គោលនយោបាយជាតិ វិធានការ និង

  (២) ស្វែងយល់ពីបញ្ហាប្រឈម/ឧបសគ្គ និងវិធានការទាំងឡាយក្នុងការដោះស្រាយបញ្ហាស្រ្តី

- ចូលរួមជាវាគ្មិនកិត្តិយស៖

  (១) ក្នុងកិច្ចពិភាក្សា នៃវេទិកាអបអរសាទរទិវានារីអន្តរជាតិលើកទី១១២ ប្រធានបទស្តីពី «បន្លឺសំឡេងស្ត្រីអ្នកដឹកនាំដើម្បីយុត្តិធម៌យេនឌ័រ»

  (២) ក្នុងវេទិកាពិភាក្សាស្តីពី “Women Empowerment in Diplomacy”

  (៣) ក្នុងកិច្ចពិភាក្សាពហុភាគី ក្រោមប្រធានបទ ស្តីពី «ឱកាសស្មើគ្នារវាងស្ត្រី និងបុរសនៅកម្រិតធ្វើសេចក្តីសម្រេចចិត្តទាំងក្នុងវិស័យសាធារណៈ និងនយោបាយ»

  (៤) ″ស្រ្តីក្នុងវិស័យសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសបរិវត្តកម្មឌីជីថល និងការរៀបចំរដ្ឋាភិបាលឌីជីថល″ និង

  (៥) ចូលរួមវេទិកាជាតិស្តីពី″ស្រ្តីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច″។

- ចុះហត្ថលេខាលើផែនការសកម្មភាពរួម រវាងក្រសួងមុខងារសាធារណៈ និងក្រសួងកិច្ចការនារីសម្រាប់ឆ្នាំ២០២៣
- ចូលរួមជាវាគ្មិន ចែករំលែកទស្សនទានក្នុងប្រធានបទតារាងស្ថិតិមន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ រហូតដល់ថ្នាក់អគ្គនាយកនិងថ្នាក់ស្មើ ឆ្នាំ២០២៤
- គិតត្រឹមដើមឆ្នាំ២០២៤ ចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រី នៅទូទាំងប្រទេស មានប្រមាណ ៥២ភាគរយ នៃចំនួនមន្ត្រីរាជការស៊ីវិលសរុប ក្នុងនោះអត្រាភាគរយមន្ត្រីរាជការជាស្ត្រីបម្រើការងារនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិមានប្រមាណ ៣១% និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានប្រមាណ ៤១,៥៥%។
- ដោយឡែក មន្ត្រីរាជការជាស្ត្រីដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យរហូតដល់ថ្នាក់អគ្គនាយក និងថ្នាក់ស្មើ មានប្រមាណ ២៧% ។ ព័ត៌មានបន្ថែមមានក្នុងតារាង៣

## តារាង៣. តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ជាស្ត្រីដែលមានមុខតំណែង គ្រប់គ្រងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤

| ល.រ | ក្រសួង-ស្ថាប័ន | អគ្គលេខាធិការដ្ឋាន / អគ្គនាយកដ្ឋាន | | | | អគ្គាធិការដ្ឋាន | | | | | | | | នាយកដ្ឋាន និងថ្នាក់ស្មើ | | | | ការិយាល័យថ្នាក់ជាតិ និងថ្នាក់ស្មើ | | | | រដ្ឋបាលសាលារាជធានី/ខេត្ត មន្ទីររាជធានី/ខេត្ត | | | | ការិយាល័យតាម មន្ទីររាជធានី/ខេត្ត | | | | ការិយាល័យតាម ក្រុង/ស្រុក/ខណ្ឌ | | | | សរុបរួម | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អគ្គលេខាធិការ / អគ្គនាយក | | អគ្គលេខាធិការរង / អគ្គនាយករង | | អគ្គាធិការ | | អគ្គាធិការរង | | អធិការ | | អធិការរង | | ប្រធាននាយកដ្ឋាន | | អនុប្រធាននាយកដ្ឋាន | | ប្រធានការិយាល័យ | | អនុប្រធានការិយាល័យ | | នាយករដ្ឋបាល ប្រធានមន្ទីរ | | នាយករងរដ្ឋបាល អនុប្រធានមន្ទីរ | | ប្រធានការិយាល័យ | | អនុប្រធានការិយាល័យ | | ប្រធានការិយាល័យ | | អនុប្រធានការិយាល័យ | | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | ស្រី |
| 1 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 0 | 37 | 8 | 1 | 11 | 1 | 11 | 1 | 9 | 0 | 72 | 6 | 211 | 38 | 325 | 55 | 889 | 282 | 24 | 0 | 101 | 15 | 293 | 39 | 392 | 124 | 106 | 9 | 6 | 0 | 6 | 0 | 2,464 | 608 | 25 |
| 2 | អធិការកិច្ច | 0 | 20 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 15 | 0 | 102 | 33 | 43 | 9 | 148 | 62 | 25 | 2 | 66 | 12 | 52 | 18 | 99 | 40 | 0 | 0 | 0 | 0 | 0 | 0 | 556 | 196 | 35 |
| 3 | អាកាសចរស៊ីវិល | 0 | 31 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 21 | 1 | 161 | 44 | 110 | 13 | 269 | 96 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 567 | 185 | 33 |
| 4 | ក្រសួងមុខងារសាធារណ: | 0 | 22 | 4 | 1 | 8 | 0 | 14 | 5 | 0 | 0 | 33 | 3 | 189 | 62 | 97 | 36 | 97 | 44 | 25 | 1 | 67 | 21 | 68 | 17 | 110 | 49 | 0 | 0 | 0 | 0 | 0 | 0 | 712 | 261 | 37 |
| 5 | ពាណិជ្ជកម្ម | 0 | 46 | 6 | 0 | 6 | 2 | 0 | 0 | 0 | 0 | 26 | 0 | 231 | 52 | 249 | 56 | 514 | 180 | 25 | 1 | 69 | 18 | 70 | 22 | 121 | 50 | 0 | 0 | 0 | 0 | 0 | 0 | 1,317 | 427 | 32 |
| 6 | ទីស្តីការគណៈរដ្ឋមន្ត្រី | 1 | 18 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 107 | 21 | 210 | 54 | 115 | 36 | 142 | 39 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 576 | 168 | 29 |
| 7 | ក្រសួងធម្មការ និងសាសនា | 0 | 20 | 1 | 0 | 0 | 0 | 1 | 0 | 4 | 1 | 21 | 0 | 55 | 11 | 53 | 13 | 80 | 37 | 25 | 0 | 67 | 10 | 85 | 16 | 121 | 44 | 0 | 0 | 1 | 0 | 1 | 0 | 515 | 152 | 30 |
| 8 | ក្រសួងវប្បធម៌ និង វិចិត្រសិល្ប: | 0 | 23 | 4 | 0 | 0 | 0 | 0 | 0 | 2 | 1 | 39 | 4 | 131 | 35 | 126 | 41 | 313 | 120 | 25 | 4 | 63 | 18 | 148 | 46 | 207 | 96 | 0 | 0 | 1 | 0 | 1 | 0 | 1,060 | 388 | 37 |
| 9 | សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | 0 | 63 | 12 | 0 | 2 | 1 | 0 | 0 | 0 | 0 | 130 | 18 | 421 | 67 | 974 | 156 | 1,426 | 410 | 25 | 2 | 67 | 15 | 188 | 59 | 315 | 151 | 2 | 1 | 2 | 1 | 2 | 1 | 3,566 | 945 | 27 |
| 10 | អប់រំ យុវជន និង កីឡា | 1 | 42 | 4 | 1 | 4 | 0 | 1 | 0 | 4 | 0 | 87 | 11 | 169 | 31 | 1,198 | 200 | 6 | 2 | 24 | 1 | 68 | 18 | 204 | 27 | 403 | 110 | 13 | 0 | 19 | 6 | 19 | 6 | 2,224 | 455 | 20 |
| 11 | ក្រសួងបរិស្ថាន | 0 | 23 | 2 | 1 | 5 | 0 | 10 | 1 | 0 | 0 | 36 | 2 | 155 | 38 | 157 | 49 | 238 | 83 | 25 | 0 | 70 | 10 | 136 | 16 | 237 | 48 | 1 | 0 | 1 | 0 | 2 | 0 | 1,075 | 271 | 25 |
| 12 | ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 0 | 24 | 3 | 1 | 3 | 1 | 0 | 0 | 0 | 0 | 35 | 5 | 110 | 31 | 92 | 37 | 116 | 42 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 359 | 141 | 39 |
| 13 | សុខាភិបាល | 0 | 19 | 2 | 1 | 7 | 0 | 0 | 0 | 0 | 0 | 16 | 2 | 69 | 16 | 928 | 242 | 92 | 34 | 22 | 1 | 102 | 12 | 41 | 4 | 43 | 12 | 1 | 1 | 0 | 0 | 0 | 0 | 1,323 | 344 | 26 |
| 14 | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា | 1 | 32 | 4 | 1 | 5 | 0 | 8 | 0 | 0 | 0 | 35 | 9 | 132 | 27 | 146 | 38 | 225 | 88 | 25 | 0 | 66 | 13 | 110 | 24 | 168 | 61 | 2 | 0 | 3 | 0 | 3 | 0 | 933 | 293 | 31 |
| 15 | ក្រសួងព័ត៌មាន | 2 | 46 | 10 | 0 | 0 | 0 | 1 | 0 | 2 | 1 | 25 | 1 | 245 | 83 | 98 | 29 | 279 | 106 | 25 | 7 | 60 | 13 | 105 | 32 | 197 | 94 | 2 | 1 | 2 | 2 | 2 | 2 | 1,055 | 417 | 40 |
| 16 | មហាផ្ទៃ | 1 | 29 | 5 | 0 | 11 | 1 | 0 | 0 | 0 | 0 | 268 | 36 | 193 | 44 | 409 | 87 | 393 | 117 | 26 | 1 | 505 | 60 | 804 | 201 | 977 | 355 | 2,564 | 552 | 2,424 | 815 | 2,364 | 784 | 10,944 | 3,082 | 28 |
| 17 | ក្រសួងយុត្តិធម៌ | 0 | 18 | 7 | 1 | 1 | 0 | 8 | 1 | 0 | 0 | 63 | 19 | 130 | 35 | 172 | 83 | 202 | 89 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 583 | 246 | 42 |
| 18 | ផែនការ | 0 | 26 | 4 | 1 | 12 | 3 | 20 | 5 | 0 | 0 | 9 | 2 | 261 | 88 | 101 | 35 | 306 | 128 | 24 | 4 | 75 | 19 | 123 | 28 | 258 | 101 | 0 | 0 | 5 | 1 | 5 | 1 | 1,203 | 442 | 37 |
| 19 | ប្រៃសណីយ៍ និងទូរគមនាគមន៍ | 0 | 23 | 3 | 1 | 4 | 2 | 0 | 0 | 0 | 0 | 36 | 4 | 128 | 32 | 97 | 30 | 160 | 64 | 23 | 5 | 54 | 13 | 74 | 20 | 107 | 47 | 1 | 1 | 1 | 0 | 1 | 0 | 689 | 242 | 35 |
| 20 | ក្រសួងសាធារណៈការ និង ដឹកជញ្ជូន | 0 | 39 | 8 | 1 | 6 | 1 | 7 | 1 | 14 | 7 | 35 | 4 | 171 | 30 | 160 | 37 | 405 | 89 | 25 | 0 | 93 | 10 | 222 | 32 | 415 | 109 | 17 | 2 | 14 | 8 | 14 | 8 | 1,606 | 378 | 24 |
| 21 | ព្រះបរមរាជវាំង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 5 | 1 | 110 | 23 | 42 | 7 | 110 | 17 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 267 | 48 | 18 |
| 22 | អភិវឌ្ឍន៍ជនបទ | 0 | 21 | 5 | 0 | 11 | 2 | 2 | 0 | 15 | 4 | 11 | 1 | 116 | 30 | 61 | 14 | 229 | 92 | 24 | 1 | 85 | 9 | 222 | 40 | 273 | 93 | 0 | 0 | 0 | 0 | 0 | 0 | 1,054 | 307 | 29 |
| 23 | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 3 | 31 | 9 | 1 | 5 | 2 | 13 | 2 | 0 | 0 | 31 | 3 | 170 | 56 | 138 | 58 | 182 | 91 | 25 | 3 | 56 | 16 | 133 | 41 | 221 | 110 | 5 | 1 | 6 | 1 | 6 | 1 | 1,003 | 417 | 42 |
| 24 | ក្រសួងទេសចរណ៍ | 0 | 50 | 12 | 0 | 9 | 1 | 4 | 0 | 0 | 0 | 15 | 1 | 124 | 40 | 104 | 42 | 169 | 76 | 24 | 1 | 66 | 20 | 134 | 42 | 168 | 82 | 0 | 0 | 0 | 0 | 0 | 0 | 829 | 355 | 43 |
| 25 | រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | 0 | 23 | 2 | 1 | 5 | 0 | 0 | 0 | 0 | 0 | 33 | 4 | 142 | 26 | 85 | 25 | 196 | 61 | 25 | 0 | 93 | 15 | 112 | 7 | 251 | 45 | 1 | 0 | 3 | 0 | 3 | 0 | 951 | 207 | 22 |
| 26 | ធនធានទឹក និង ឧតុនិយម | 0 | 4 | 0 | 1 | 3 | 1 | 0 | 0 | 0 | 0 | 22 | 0 | 58 | 6 | 59 | 8 | 193 | 51 | 25 | 0 | 63 | 6 | 94 | 8 | 148 | 35 | 2 | 0 | 0 | 0 | 0 | 0 | 667 | 120 | 18 |
| 27 | ក្រសួងកិច្ចការនារី | 2 | 11 | 9 | 0 | 2 | 1 | 0 | 0 | 0 | 0 | 13 | 10 | 37 | 32 | 41 | 28 | 67 | 49 | 25 | 25 | 69 | 55 | 152 | 126 | 118 | 90 | 2 | 2 | 1 | 1 | 1 | 1 | 539 | 431 | 80 |
| 28 | តុលាការកំពូល | 1 | 4 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 1 | 6 | 2 | 9 | 2 | 2 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 23 | 11 | 48 |
| 29 | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 1 | 52 | 6 | 1 | 18 | 2 | 32 | 5 | 0 | 0 | 122 | 17 | 395 | 85 | 209 | 56 | 557 | 210 | 25 | 0 | 74 | 21 | 129 | 29 | 196 | 81 | 0 | 0 | 0 | 0 | 0 | 0 | 1,764 | 559 | 32 |
| 30 | អង្គភាពប្រឆាំងអំពើពុករលួយ | 0 | 5 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 8 | 0 | 33 | 9 | 30 | 12 | 71 | 17 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 144 | 43 | 30 |
| 31 | រ៉ែ និងថាមពល | 0 | 12 | 1 | 1 | 4 | 0 | 5 | 0 | 0 | 0 | 22 | 5 | 89 | 20 | 99 | 19 | 157 | 43 | 24 | 2 | 62 | 6 | 90 | 18 | 103 | 27 | 7 | 0 | 2 | 0 | 2 | 0 | 667 | 153 | 23 |
| 32 | សាលាឧទ្ធរណ៍ | 1 | 10 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 14 | 3 | 32 | 12 | 13 | 7 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 66 | 32 | 48 |
| | **សរុប គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤** | *14* | *824* | *150* | *16* | *142* | *21* | *137* | *21* | *50* | *14* | *1,409* | *194* | *4,786* | *1,192* | *6,540* | *1,560* | *8,236* | *2,821* | *590* | *61* | *2,161* | *425* | *3,789* | *912* | *5,648* | *2,054* | *2,726* | *570* | *2,491* | *835* | *2,432* | *804* | *41,301* | *12,324* | |
| | **គិតជាភាគរយ (%)** | 100 | 5886 | 100 | 11 | 100 | 15 | 100 | 15 | 100 | 28 | 100 | 14 | 100 | 25 | 100 | 24 | 100 | 34 | 100 | 10 | 100 | 20 | 100 | 24 | 100 | 36 | 100 | 21 | 100 | 34 | 100 | 33 | 100 | 30 | |

## ខ.១.២. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ

ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១២ មានចំនួន ៩២នាក់/ស្ត្រី ៣១នាក់ សិក្សាចំនួន ២ឆ្នាំ បានបញ្ចប់ការសិក្សាតាមការកំណត់ និងកំពុងរៀបចំឯកសារសម្រាប់ការពាររបាយការណ៍បញ្ចប់របស់សិស្សមន្ត្រីជាន់ខ្ពស់
- សិស្សមន្ត្រីក្រមការជំនាន់ទី១០ មានចំនួន ១២២នាក់/ស្ត្រី ៣៨នាក់ បានបញ្ចប់ការសិក្សាតាមការកំណត់ និងកំពុងរៀបចំឯកសារសម្រាប់ការពាររបាយការណ៍បញ្ចប់របស់សិស្សមន្ត្រី
- សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មី ឆ្នាំ២០២១ បានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យជាស្ថាពរ ចំនួន ៧១៣នាក់/ស្ត្រី ២៩១នាក់ ក្នុងនោះសិស្សក្រមការ ចំនួន ៥៩នាក់/ស្ត្រី ២៨នាក់
- សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មី ឆ្នាំ២០២២ មានចំនួនសរុប ៦១៨នាក់/ស្ត្រី ២៤៤នាក់ និងសិស្សក្រមការ ចំនួន ៧៩នាក់/ស្ត្រី ៣០នាក់
- សិស្សមន្ត្រីក្របខណ្ឌថ្មីក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៣មាន ចំនួន ១០០នាក់/ស្ត្រី ៣៤នាក់
- បណ្តុះបណ្តាលកម្មសិក្សាការីវគ្គវិក្រឹតការសម្រាប់ឆ្នាំ២០២៣ រួមមាន៖
  - ✎ វគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ចំនួន ១៨៦នាក់/ស្ត្រី ២៣នាក់ ព្រះសង្ឃ ២០អង្គ
  - ✎ វគ្គវិក្រឹតការមន្ត្រីមធ្យម ចំនួន ៣០៧នាក់/ស្ត្រី ៦៩នាក់
  - ✎ វគ្គវិក្រឹតការមន្ត្រីគ្រប់គ្រងរដ្ឋបាល ចំនួន ៧៥នាក់/ស្ត្រី ២៥នាក់ ព្រះសង្ឃ ៧អង្គ
  - ✎ វគ្គវិក្រឹតការមន្ត្រីក្រមការ ចំនួន ២០នាក់/ស្ត្រី ៧នាក់
- រៀបចំកម្មវិធីបាឋកថា ចំនួន ៦កម្មវិធី ដែលមានអ្នកចូលរួម សរុបចំនួន ៨២២អង្គ/នាក់ / ស្ត្រី២០០នាក់ ដោយក្នុងនោះអ្នកចូលរួមផ្ទាល់មាន ចំនួន ៤៤០អង្គ/នាក់ / ស្ត្រី៧១នាក់ និង ព្រះសង្ឃ៨អង្គ
- រៀបចំកម្មវិធីចែករំលែកដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញស្តីពី "មជ្ឈមណ្ឌលត្រៀមប្រឡងប្រជែងចូលសាលារដ្ឋបាលនៅប្រទេសបារាំង" ដោយសហការជាមួយទីភ្នាក់ងារឧត្តមសិក្សាប្រើប្រាស់ភាសាបារាំង ស្ថានទូតបារាំង និងវិទ្យាស្ថានសិក្សានយោបាយទីក្រុងលីយ៉ុង នៅសហសាលសាលាភូមិន្ទរដ្ឋបាល សិក្ខាកាមចូលរួមសរុប ចំនួន ៣៥នាក់/ស្ត្រី៨នាក់
- រៀបចំសិក្ខាសាលាស្តីពី " រដ្ឋបាលនវានុវត្តន៍ និងរដ្ឋតាមបែប Neo – Weberian ៖ ទស្សនវិស័យថ្មី" នៅសាលាភូមិន្ទរដ្ឋបាល មានសិក្ខាកាមចូលរួមដោយផ្ទាល់ ចំនួន ១៣៥នាក់/ស្ត្រី៣៦នាក់ និងតាមប្រព័ន្ធអនឡាញ សរុបចំនួន ៩០០អង្គ/នាក់
- រៀបចំសន្និសីទអន្តរជាតិរដ្ឋបាល ស្តីពី "បរិវត្តកម្មរដ្ឋបាលសាធារណៈ ក្នុងបរិការណ៍នៃការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម" ដែលរៀបចំនៅរសៀលថ្ងៃទី២ និងទី៣ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ SUN & MOON Riverside ដែលមានសិក្ខាកាមចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ចំនួន ៣០០នាក់
- រៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ចំនួន ៩វគ្គ៖ (១)ជំនាញរដ្ឋបាលសាធារណៈ វគ្គទី៨ មានសិក្ខាកាមសរុបចំនួន ១០៧នាក់/ស្ត្រី ១៨នាក់ និងវគ្គទី៩ ចំនួន១០០នាក់/ស្ត្រី ២២នាក់ (២)ជំនាញតាក់តែងលិខិតរដ្ឋបាល និងបទដ្ឋានគតិយុត្ត វគ្គទី៤ មានសិក្ខាកាមសរុបចំនួន ១០២នាក់/ស្ត្រី ២៩នាក់ និងវគ្គទី៥ ចំនួន ១០១នាក់/ស្ត្រី ២៧នាក់ (៣)នវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ វគ្គទី៨ បានបញ្ចប់វគ្គបណ្តុះបណ្តាល និងបានប្រឡងបញ្ចប់តាមប្រព័ន្ធអនឡាញដោយទទួលបានជោគជ័យ ចំនួន ៤០អង្គ/នាក់ (ស្ត្រី ៥នាក់ ព្រះសង្ឃ ១អង្គ) (៤)ជំនាញគ្រប់គ្រងអង្គភាពសាធារណៈ វគ្គទី៧ មានសិក្ខាកាម សរុបចំនួន ៨០នាក់/ស្ត្រី១២នាក់ (៥)វគ្គថ្នាក់ដឹកនាំនៃមន្ទីរមុខងារសាធារណៈមានសិក្ខាកាម ចំនួន ១០០នាក់/ស្ត្រី ២៧នាក់ (៦)វគ្គមន្ត្រីគ្រប់គ្រង នៃក្រសួង ស្ថាប័ន មានសិក្ខាកាម ចំនួន ៣២នាក់/ស្ត្រី ៤នាក់ និង(៧)វគ្គថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ន មានសិក្ខាកាម ចំនួន ៣៨នាក់/ស្ត្រី ៦នាក់

- ចូលរួមជាវាគ្មិនសម្រាប់កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "មុខជំនាញសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលប្រើប្រាស់ភាសាបារាំង" ដែលបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នៅតាមបណ្ដាថ្នាក់ពីរភាសានៅតាមបណ្ដារាជធានី ខេត្ត ចំនួន ៦រួមមាន៖ (១)រាជធានីភ្នំពេញ (វិទ្យាល័យព្រះស៊ីសុវត្ថិ) (២)ខេត្តសៀមរាប (វិទ្យាល័យអង្គរ) (៣)ខេត្តបាត់ដំបង (វិទ្យាល័យព្រះមុនីវង្ស) (៤)ខេត្តកំពង់ចាម (វិទ្យាល័យព្រះសីហនុ) (៥)ខេត្តតាកែវ (វិទ្យាល័យដាស៊ីមតាកែវ) និង(៦)ខេត្តកណ្ដាល (វិទ្យាល័យហ៊ុនសែនសេរីភាព) ក្នុងនោះផងដែរកម្មវិធីផ្សព្វផ្សាយខាងលើ មានការចូលរួមពីសិស្សានុសិស្សប្រមាណ ៩០០នាក់ និងលោកគ្រូ អ្នកគ្រូប្រមាណ ៥០នាក់ ដែលបានផ្សព្វផ្សាយកាលពីថ្ងៃទី៤ ដល់ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣
- ទទួលសិស្ស និងមន្ត្រីចូលអាន និងស្រាវជ្រាវក្នុងបណ្ណាល័យ ៨៦៦អង្គ/នាក់ (ស្ត្រី ១៥៨នាក់)
- សិស្ស និងមន្ត្រី ចំនួន ១២១នាក់ បានខ្ចីសៀវភៅ ចំនួន ១៩៤ក្បាល និងបានសងសៀវភៅ ចំនួន ១៩៤ក្បាល
- ដាក់កូដសៀវភៅថ្មី ចំនួន ៣២៤ក្បាល និងចាស់ ចំនួន ៧ក្បាល
- ទទួលសៀវភៅថ្មី ចំនួន ៤៧៧ក្បាល
- ជួសជុលសៀវភៅចាស់បាន ចំនួន ១៦០ក្បាល
- រៀបចំអត្ថបទស្រាវជ្រាវ (ជាភាសាអង់គ្លេស) ស្តីពីមុខងារសាធារណៈកម្ពុជា កំណែទម្រង់ និងបញ្ហាប្រឈមផ្ញើជូនអាជ្ញាធរជាតិគ្រប់គ្រងបុគ្គលិកជប៉ុន(NPA) កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ សម្រាប់ចងក្រងជាសៀវភៅក្នុងសិក្ខាសាលាអន្តរជាតិក្នុងក្របខណ្ឌមុខងារសាធារណៈអាស៊ានបូក៣នាពេលខាងមុខ
- បញ្ចប់ការចងក្រងកម្រងអនុស្សាវរីយ៍របស់សាលាភូមិន្ទរដ្ឋបាល និងស្នើសុំការបោះពុម្ព
- ដាក់ឱ្យដំណើរការប្រឡងអនឡាញសម្រាប់វគ្គវិក្រឹតការ ឆ្នាំ២០២៣ និងសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មី៖ (១) វគ្គវិក្រឹតការឆ្នាំ២០២៣ ចំនួន ៧៤ដង និង (២) សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មី សិស្សមន្ត្រីក្រមការក្របខណ្ឌថ្មី ចំនួន ៥៩ដង
- ធ្វើបទបង្ហាញស្តីពីការប្រើប្រាស់កាតស្កេនវត្តមានសិស្សមន្ត្រីក្រមការជំនាន់ទី១០ និងសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១២
- បង្កើតគណនី (Microsoft Team & ប្រព័ន្ធគ្រប់គ្រងការសិក្សា LMS) សម្រាប់វគ្គវិក្រឹតការ ឆ្នាំ២០២៣ និងសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មី ឆ្នាំ២០២១ សរុបចំនួន ១,២០៨នាក់
- ដាក់ឱ្យដំណើរការប្រឡងឡើងវិញសម្រាប់សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មី ឆ្នាំ២០២១ វគ្គ២ ក្រុម២ ចំនួន ២នាក់ លើ២មុខវិជ្ជា និងបានដាក់ឱ្យក្រុមហ៊ុន POSCAR ធ្វើកាតសម្រាប់កម្មសិក្សាការីវគ្គវិក្រឹតការឆ្នាំ ២០២៣ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣
- ដាក់ប្រអប់បញ្ចេញមតិយោបល់កែលម្អ សម្រាប់សិស្សមន្ត្រី និងកម្មសិក្សាការី កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣
- សម្របសម្រួលអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាល កាលពីថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣៖ (១)សាលាបឋមសិក្សាចំនួន៤៦អង្គភាព (២)វិទ្យាល័យចំនួន៤២អង្គភាព និង(៣)មណ្ឌលសុខភាពចំនួន៤៣អង្គភាព
- សម្របសម្រួលក្នុងកម្មវិធីនានាសរុប ចំនួន ១៣កម្មវិធី
- រៀបចំអត្ថបទ និងជ្រើសរើសរូបភាពផ្សព្វផ្សាយព័ត៌មាននៅលើប្រព័ន្ធ Facebook និងគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល សរុបចំនួន ១២៦កម្មវិធី។

### ២.១.៣. ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធឌីជីថល

សមិទ្ធផលការងារសំខាន់ៗដែលសម្រេចបាន មានដូចខាងក្រោម៖

- រៀបចំសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមការងារទទួលបន្ទុករៀបចំសិក្ខាសាលាក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងបរិវត្តកម្មនៃឌីជីថលូបនីយកម្មក្នុងរដ្ឋបាលសាធារណៈនៃប្រទេសសមាជិកអាស៊ាន និងប្រទេសទីម័រខាងកើត
- បន្តសិក្សា និងរៀបអំពីស្តង់ដាសុវត្ថិភាពសម្រាប់យកមកប្រើប្រាស់ជាស្តង់ដាក្នុងការកំណត់សុវត្ថិភាពលើការអភិវឌ្ឍប្រព័ន្ធឌីជីថល និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល៖ សហការជាមួយអង្គភាពជំនាញ៖ (១) កំណត់ និងអនុវត្តនីតិវិធីក្នុងការចូលទៅបន្ទប់មជ្ឈមណ្ឌលទិន្នន័យ (២)ដំឡើងម៉ាស៊ីនមេនិម្មិត (Virtual Machines) សម្រាប់ប្រព័ន្ធគ្រប់គ្រងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីរាជការស៊ីវិល (៣)ដំឡើងម៉ាស៊ីនមេនិម្មិត (Virtual Machines) សម្រាប់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) (៤)ដំឡើងប្រព័ន្ធ VPN ថ្មីសម្រាប់ឱ្យក្រសួងស្ថាប័នទាំង៨ អាចភ្ជាប់មកកាន់ប្រព័ន្ធ HRMIS និងប្រព័ន្ធគ្រប់គ្រងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសារមន្ត្រីរាជការស៊ីវិល (៥)បង្កើតម៉ាស៊ីនមេសម្រាប់បម្រុងទុក (Backup Servers) ដោយធ្វើការរក្សាទុកមូលដ្ឋានទិន្នន័យស្នូល (Core Database) និង ម៉ាស៊ីនមេនិម្មិត (Virtual Machines ) (៦)រៀបចំប្រព័ន្ធបណ្តាញ(NETWORK)នៅក្នុងក្រសួងដើម្បីធានាបាននៅការប្រើប្រាស់ដោយសុវត្ថិភាព និងប្រសិទ្ធភាព ដំឡើងម៉ាស៊ីនមេ សម្រាប់ការងារ Data Warehouse (៧)បង្កើតម៉ាស៊ីនមេ និងរៀបចំផែនការ ដើម្បីផ្លាស់ទីគេហទំព័ររបស់ក្រសួងមុខងារសាធារណៈ www.mcs.gov.kh ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មកដាក់នៅក្រសួងមុខងារសាធារណៈ
- ពិនិត្យនិងបោះពុម្ពអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល៖ (១)ស្នើសុំចំនួន១១,៥១០នាក់/ស្ត្រី៣,៩៤៩នាក់ (២)បានបោះពុម្ពចំនួន១៣,៤៨៦នាក់/ស្ត្រី ២,៧៧៥នាក់
- តបណ្តាញ និងបង្កើតគណនីជូនអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ ដើម្បីចូលប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា និងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សជូនមន្ត្រីរាជការស៊ីវិល
- បន្ថែមផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ប្រព័ន្ធបោះពុម្ពអត្តសញ្ញាណបណ្ណមន្ត្រីរាជការប្រភេទថ្មី សម្រាប់មន្ទីរមុខងារសាធារណៈ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- កែលម្អផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ សម្រាប់ការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ MCS Mobile App និងបានកែលម្អផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ សម្រាប់ការរៀបចំអត្តសញ្ញាណបណ្ណមន្ត្រីរាជការប្រភេទថ្មី
- ដាក់ឱ្យអនុវត្តធ្វើការបម្រែបម្រួលស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីរាជការ និងបោះពុម្ពតារាងទូទាត់បៀវត្សក្នុងប្រព័ន្ធ HRMIS ថ្មី ចំនួន១៣ ក្រសួង ស្ថាប័ន
- រៀបចំអត្តលេខជូនមន្ត្រីរាជការស៊ីវិលក្នុងប្រព័ន្ធព័ត៌មានវិទ្យាចំនួន ៣,៦០១នាក់
- ផ្តល់ទិន្នន័យចំនួនមន្ត្រីរាជការស៊ីវិលនិងប្រាក់បៀវត្សមូលដ្ឋាន ចំនួនមន្ត្រីជាប់កិច្ចសន្យា និងប្រាក់កម្រៃនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៣ និងខែមករា និងខែកុម្ភៈ ឆ្នាំ២០២៤ ជូនបេឡាជាតិសន្តិសុខ សង្គម
- ផ្តល់ទិន្នន័យចំនួនសមាជិករាជរដ្ឋាភិបាល រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សាជំនួយការ និងមន្ត្រីខុទ្ទកាល័យដែលតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ដែលមិនស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងប្រាក់លាភការឬប្រាក់កម្រៃសម្រាប់ធ្វើជាទិន្នន័យក្នុងការវិភាគ និងពង្រីកវិសាលភាពរបស់សន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព ជូនបេឡាជាតិសន្តិសុខសង្គម
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តនីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត សម្រាប់ខែមករា និងខែកុម្ភៈ ឆ្នាំ២០២៤ ជូនខុទ្ទកាល័យ **សម្តេចធិបតី នាយករដ្ឋមន្ត្រី**

- ផ្តល់ទិន្នន័យលទ្ធផលក្របខណ្ឌតាមដាន និងវាយតម្លៃសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលកម្ពុជាសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ ឆ្នាំ២០២៤ ជូនគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមរៀបចំវេទិការដ្ឋាភិបាលឌីជីថលឆ្នាំ២០២៤ និងពិព័រណ៍រដ្ឋាភិបាលឌីជីថលនិងបច្ចេកវិទ្យាកម្ពុជា-អន្តរជាតិ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ
- រៀបចំលិខិតឆ្លើយតបស្តីពីសំណើសុំកិច្ចសហការនិងប្រើប្រាស់ថ្នាលបញ្ជូនសារពហុទិសដៅរបស់រាជរដ្ឋាភិបាល (nomsa.gov.kh)
- រៀបចំរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍តាមអាយុ នៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ មន្ទីរ អង្គភាពនៅថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ខែកុម្ភៈ មីនា មេសា ឧសភា មិថុនា និងខែកក្កដា ឆ្នាំ២០២៤ ចំនួនសរុប ៨៦៩នាក់
- បោះពុម្ពសលាកបត្រមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍តាមអាយុ ថ្នាក់ក្រោមជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ខែកុម្ភៈ មីនា មេសា ឧសភា មិថុនា និងខែកក្កដា ឆ្នាំ២០២៤ ចំនួនសរុប ៨៩១នាក់
- ធ្វើការកែប្រែរូបរាង និងដោះស្រាយបញ្ហា (UX/UI) MCS Mobile App ឱ្យកាន់តែស្រួលប្រើជាងមុនទាំងផ្នែកខាងក្នុង និងក្រៅ
- ធ្វើការ mapping domain និងបង្ហោះគេហទំព័រ www.job.mcs.gov.kh និង www.jobuat.mcs.gov.kh
- គ្រប់គ្រងប្រព័ន្ធ VPN សម្រាប់ឱ្យក្រសួង ស្ថាប័ន ចំនួន០៨ ក្នុងនោះមាន៖ ក្រសួងទេសចរណ៍ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី អាចភ្ជាប់មកកាន់ប្រព័ន្ធ HRMIS និងប្រព័ន្ធគ្រប់គ្រង ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសារមន្ត្រីរាជការស៊ីវិល
- បង្កើត និងបន្តការអភិវឌ្ឍន៍កម្មវិធី (MCSDC) សម្រាប់គ្រប់គ្រងសលាកបត្រព័ត៌មាន របស់មន្ត្រីរាជការស៊ីវិល
- រៀបចំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ Network ក្នុងទីស្តីការក្រសួងមុខងារសាធារណៈ និង ដំឡើងកម្មវិធី Visual Studio និង MySQL connector/ODBC ជូនអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលកិច្ចប្រជុំតាមដានវឌ្ឍនភាព នៃការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា (២០២២-២០៣៥) និងការងារកសាងរដ្ឋាភិបាលឌីជីថល
- បង្កើតប្រព័ន្ធដាក់ពិន្ទុឱ្យការប្រឡងគ្រូកីឡាថ្នាក់ជាតិ និងដាក់ឱ្យប្រើប្រាស់ដោយជោគជ័យ
- រៀបចំការធ្វើកោសល្យវិច្ច័យ ចរាចរណ៍ទិន្នន័យ ដែលមិនប្រក្រតីឬការវាយប្រហារមកលើហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីស្វែងរកចំណុចខ្សោយនៅលើថ្នាលឌីជីថលនិងឧបករណ៍បណ្តាញផ្សេងៗ
- បាននិងកំពុងសិក្សា និងកសាងថ្នាលព័ត៌មានការងារក្នុងរដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់សិស្ស និស្សិត និងសាធារណជនស្វែងរកការងារក្នុងរដ្ឋបាលសាធារណៈ និងចុះឈ្មោះប្រឡងប្រជែងតាម Online
- អភិវឌ្ឍន៍មុខងារ login ជាមួយកម្មវិធី CamDigiKey សម្រាប់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល
- គាំទ្រការប្រើប្រាស់ប្រព័ន្ធថ្មី HRMIS និង Payroll ដល់អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ
- រៀបចំ Interface សម្រាប់មុខងារ Scan QR ចុះវត្តមានកិច្ចប្រជុំ និង Smart Card

### ខ.១.៤. កិច្ចការគោលនយោបាយមុខងារសាធារណៈ

តារាង៤. ដំឡើងបៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ

| ១. ការដំឡើងបៀវត្សអប្បបរមារសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ | | |
|---|---|---|
| **បរិយាយ** | **២០២៣** | **២០២៤** |
| វិស័យរដ្ឋបាល បច្ចេកទេស និងការទូត | ១ ៣០០ ០០០ | ១ ៣៥៦ ៩៥០ |
| វិស័យអប់រំ | ១ ៤០០ ០០០ | ១ ៤៥៦ ៩៥០ |
| វិស័យសុខាភិបាល | ១ ៤០០ ០០០ | ១ ៤៥៦ ៩៥០ |
| នគរបាលជាតិ | ១ ៣៨៤ ៤៧៧ | ១ ៤៤៣ ៩២៧ |
| យោធិន | ១ ៣០៩ ៤៧៧ | ១ ៣៦៥ ០២៧ |
| **២. ការដំឡើងប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា** | | |
| **បរិយាយ** | **២០២៣** | **២០២៤** |
| មន្ត្រីជាប់កិច្ចសន្យា | ៧១០ ០០០ | ៧៧០ ០០០ |
| **៣. ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ក្រុមប្រឹក្សា និងមន្ត្រីភូមិ** | | |
| **បរិយាយ** | **២០២៣** | **២០២៤** |
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ ៥៧០ ០០០ | ១ ៦៥០ ០០០ |
| សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | ១ ១៩៥ ០០០ | ១ ២៤៥ ០០០ |
| ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ១ ២៨៥ ០០០ | ១ ៣៦៥ ០០០ |
| សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៩៧០ ០០០ | ១ ០២០ ០០០ |
| ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ | ១ ២៤០ ០០០ | ១ ៣២០ ០០០ |
| ជំទប់ទី១-ទី២ ចៅសង្កាត់រងទី១-ទី២ | ៩៣០ ០០០ | ៩៨០ ០០០ |
| សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ៨២០ ០០០ | ៨៧០ ០០០ |
| មេភូមិ | ៥១០ ០០០ | ៥៥០ ០០០ |
| អនុប្រធានភូមិ | ៣៩០ ០០០ | ៤៣០ ០០០ |
| មន្ត្រីភូមិ | ៣៦០ ០០០ | ៤០០ ០០០ |

#### ខ.១.៤.១.ការងារគោលនយោបាយអភិវឌ្ឍវិស័យមុខងារសាធារណៈ

ការងារគោលនយោបាយអភិវឌ្ឍវិស័យមុខងារសាធារណៈ សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- សិក្សាទិន្នន័យមន្ត្រីរាជការត្រូវដំឡើងបៀវត្សតាមវិស័យ និងបានប្រមូលឯកសារ (Desk Review) ពាក់ព័ន្ធនឹងគោលនយោបាយគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- ស្រាវជ្រាវ រៀបចំ និងពិនិត្យឡើងវិញដើម្បីធ្វើបច្ចុប្បន្នភាពលើសៀវភៅព័ត៌មានសម្រាប់មន្ត្រីរាជការស៊ីវិល
- ធ្វើការស្រាវជ្រាវអំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងប្រព័ន្ធបៀវត្សរបស់ប្រទេសកូរ៉េ ម៉ាឡេស៊ី និងសិង្ហបុរី

- រៀបចំសេចក្តីព្រាងឯកសារ និងបទដ្ឋានគតិយុត្តចំនួន ៣ ដូចខាងក្រោម៖
  ១. សេចក្តីព្រាងឯកសារណែនាំ និងអនុក្រឹត្យស្តីពីការរៀបចំការពិពណ៌នាមុខតំណែង
  ២. សេចក្តីព្រាងឯកសារណែនាំ និងអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
  ៣. សេចក្តីព្រាងក្របខ័ណ្ឌការអភិវឌ្ឍសមត្ថភាព ភាពជាអ្នកដឹកនាំសម្រាប់អ្នកគ្រប់គ្រងកម្រិតនាយកដ្ឋាន
- រៀបចំដំឡើងបៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែជូនមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីជាប់កិច្ចសន្យា សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ ដូចខាងក្រោម ៖

**ខ.១.៤.២. ការងារគោលនយោបាយសេវាសាធារណៈ**

ការងារគោលនយោបាយសេវាសាធារណៈ សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- សម្របសម្រួលដល់គណៈកម្មការបច្ចេកទេសអន្តរក្រសួងនៃ គ.វ.ជ. និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ (គ.វ.ជ.) ក្នុងកិច្ចដំណើរការនៃការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៣ ដែលមានបេក្ខភាពចូលរួម (បេក្ខភាពដែលគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ខេត្ត)៖ អនុវិទ្យាល័យ ចំនួន៤២ សាលាបឋមសិក្សា ចំនួន៤៦ និងមណ្ឌលសុខភាព ចំនួន៤៣
- សហការសម្របសម្រួលរៀបចំប្រកាសអន្តរក្រសួងចំនួន២ (ប្រកាសអន្តរក្រសួងលេខ៣៨៤/២៤ មស.គវជ និងប្រកាសអន្តរក្រសួងលេខ៣៨៥/២៤ មស.គវជ) និងធ្វើបច្ចុប្បន្នភាពតារាងលក្ខណៈវិនិច្ឆ័យចំនួន៥ ព្រមទាំងឯកសារណែនាំស្តីពីវិធីសាស្ត្រសម្រាប់ការវាយតម្លៃនិងទទួលស្គាល់វិទ្យាល័យ សាលាមត្តេយ្យសិក្សា មន្ទីរពេទ្យបង្អែកថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ (CPA1) កម្រិត២ (CPA2) និងកម្រិត៣ (CPA3)
- ចូលរួមសហការរៀបចំដំណើរទស្សនកិច្ចសិក្សាលើកទី២ របស់មន្ត្រីរាជការអាស៊ានទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ក្រោមគម្រោង "ការរៀបចំឯកសារណែនាំអាស៊ាន ស្តីពីការផ្តល់សេវាសាធារណៈ" នៃផែនការការងារឆ្នាំ២០២១-២០២៥ ក្នុងកិច្ចសហប្រតិបត្តិការអាស៊ានបូក៣ លើវិស័យមុខងារសាធារណៈ

**ខ.១.៤.៣. កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិ វិស័យមុខងារសាធារណៈ**

កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិ វិស័យមុខងារសាធារណៈសម្រេចបានលទ្ធផលដូចខាងក្រោម៖

- រៀបចំ និងសម្របសម្រួលចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងស្រុក ចំនួន ០៤វគ្គ សរុប ០៨នាក់ (ស្ត្រី ០២នាក់)
- រៀបចំ និងសម្របសម្រួលចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា និងអាហារូបករណ៍ក្រៅប្រទេស ចំនួន ៣០វគ្គ សរុប ៧៤នាក់ (ស្ត្រី ២១នាក់)
- សម្របសម្រួលផ្សព្វផ្សាយសេចក្តីជូនដំណឹងវគ្គអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ចំនួន ១១ កម្មវិធី
- សម្របសម្រួលចាត់បញ្ជូនគណៈប្រតិភូមុខងារសាធារណៈកម្ពុជា ចូលរួមក្នុងកិច្ចប្រជុំក្នុងប្រទេស ចំនួន ០៨ កិច្ចប្រជុំ សរុបចំនួន ៣៥នាក់ (ស្ត្រី ០៨នាក់) និងក្រៅប្រទេសចំនួន ០៦ កិច្ចប្រជុំ សរុបចំនួន ១២នាក់ (ស្ត្រី ០៣នាក់)
- រៀបចំលិខិតស្នើសុំទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីឯកសារជំនួយស្មារតី សរុបចំនួន ១១ករណី
- សម្របសម្រួលរៀបចំឯកសារបច្ចុប្បន្នភាពជំនួយស្មារតីទាំងពីរភាសា និងចូលរួមជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាងឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាមួយនឹងតំណាងស្ថានទូត

និងដៃគូអភិវឌ្ឍន៍ សរុបចំនួន ១៣ជំនួប រួមមាន៖ ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ ស្ថានទូតអូស្ត្រាលី ឥណ្ឌា តួកគី សហរដ្ឋអាមេរិក សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋឆែក ឡាវ សហភាពអឺរ៉ុប អ្នកតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ធនាគារពិភពលោក ភ្នាក់ងារកុងស៊ុលស្វីស និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េប្រចាំកម្ពុជា (KOICA)

- រៀបចំ សម្របសម្រួល និងផ្តល់ធាតុចូល/ព័ត៌មាន លើលិខិតូបករណ៍ ឯកសារទស្សនទាន និងរបាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ក្នុងកម្រិតជាតិ និងអន្តរជាតិ សរុបចំនួន ៣៧ករណី
- សិក្សាស្រាវជ្រាវ ប្រមូល និងចងក្រងឯកសារ ស្តីពីសាលាជាតិរដ្ឋបាល និងវិទ្យាស្ថានបណ្តុះបណ្តាលសេវាសាធារណៈរបស់ប្រទេសសមាជិកអាស៊ាន និងអាស៊ាន+៣ (ចិន ជប៉ុន និងកូរ៉េ) និងប្រទេសពាក់ព័ន្ធ ព្រមទាំងឯកសារស្តីពីប្រព័ន្ធលាភការ និងការលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មប្រទេសថៃ
- សម្របសម្រួលជាមួយអង្គភាពទទួលបន្ទុកគម្រោង លេខាធិការដ្ឋានអាស៊ាន និងរដ្ឋបាលជាតិមុខងារសាធារណៈ (NCSA) នៃប្រទេសចិន អនុវត្តគម្រោង ASEAN Guidelines on Public Service Delivery ដំណាក់កាលទី២ គឺការធ្វើទស្សនកិច្ចសិក្សាទៅកាន់ប្រទេសចិន (Study Visit to China) ក្រោមផែនការការងារ ACCSM+3 ២០២១-២០២៥
- សម្របសម្រួលជាមួយអង្គភាពទទួលបន្ទុកគម្រោង និងលេខាធិការដ្ឋានអាស៊ាន ដើម្បីអនុវត្តគម្រោងសិក្ខាសាលាស្តីពី Digitalization in Public Administration របស់ក្រសួងមុខងារសាធារណៈកម្ពុជា ដែលស្ថិតក្រោមផែនការការងារ ACCSM+3 ២០២១-២០២៥
- បន្តសម្របសម្រួលស្តីពីការបញ្ជូនអ្នកជំនាញឯកទេសនៃអាជ្ញាធរមូលដ្ឋានជប៉ុន ដើម្បីជួយបណ្តុះបណ្តាលដល់មន្ត្រីកម្ពុជាក្រោមគម្រោង "Local Authority International Cooperation Specialist Dispatch Project 2023" របស់អង្គការ CLAIR
- ថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ០១រូប ធ្វើបទបង្ហាញដល់សាស្ត្រាចារ្យដែលមកពីសាកលវិទ្យាល័យនៃប្រទេសជប៉ុនក្រោមគម្រោង Human Resource Development Scholarship Program របស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICE) នៅសាលាភូមិន្ទរដ្ឋបាល
- ចូលរួមសិក្ខាសាលាអន្តរជាតិក្នុងស្រុក ចំនួន ៦លើក ពាក់ព័ន្ធនឹងរដ្ឋបាលនវានុវត្តន៍ ការប្រើប្រាស់ទិន្នន័យធំ (Big Data) ការចែករំលែកព័ត៌មាន និងបទពិសោធន៍ក្នុងការទទួលបានអាហារូបករណ៍ទៅប្រទេសអូស្ត្រាលី ការបញ្ជ្រាបយេនឌ័រក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០២៤-២០២៨ សិក្ខាសាលាថ្នាក់តំបន់ស្តីពី "បរិវត្តកម្មនៃភាពជាអ្នកដឹកនាំ" និងការផ្សព្វផ្សាយច្បាប់ស្តីពីអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានសម្របសម្រួលរៀបចំឆ្លើយសំណួររបស់ ACCSM Work Plan (Post-2025 ACCSM Work Plan) សម្រាប់គម្រោង ACCSM Work Plan ឆ្នាំ២០២៥។

### ខ.១.៥. កិច្ចការអធិការកិច្ចវិស័យមុខងារសាធារណៈ

កិច្ចការអធិការកិច្ចវិស័យមុខងារសាធារណៈ សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- ផែនការអធិការកិច្ចវិស័យមុខងារសាធារណៈប្រចាំឆ្នាំ២០២៣ និងប្រចាំឆ្នាំ២០២៤ និងកម្មវិធីអធិការកិច្ច
- សេចក្តីណែនាំពាក់ព័ន្ធនឹងការងារអធិការកិច្ចមុខងារសាធារណៈ ចំនួន៥ រួមមាន៖ (១)អធិការកិច្ចលើការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា (២)អធិការកិច្ចលើការជ្រើសរើស ការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា (៣)អធិការកិច្ចលើការតែងតាំង ការប្រគល់ភារកិច្ច ការដំឡើងឋានន្តរស័ក្តិនិងថ្នាក់ ការដាក់ទណ្ឌកម្មវិន័យ ការបញ្ចប់ភារកិច្ច និងការចូលនិវត្តន៍មន្ត្រីរាជការស៊ីវិល (៤)វិធីសាស្ត្រនៃការធ្វើអធិការកិច្ចលើការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីរាជការស៊ីវិលពាក់ព័ន្ធនឹងការបង្កក

ការបង្វែរប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ និង(៥)ភារកិច្ច សិទ្ធិអំណាច របៀបរបបការងារ និងវិន័យការងាររបស់គណៈប្រតិភូ អធិការកិច្ចមុខងារសាធារណៈ
- សេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តអធិការកិច្ចវិស័យមុខងារសាធារណៈក្នុងកម្រិតបច្ចេកទេស រួមមាន៖ (១) អនុក្រឹត្យស្ដីពីអធិការកិច្ចមុខងារសាធារណៈ (២)អនុក្រឹត្យស្ដីពីនីតិវិធីនៃការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីរាជការស៊ីវិល (៣)អនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ (៤)សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ (៥)សេចក្ដីណែនាំស្ដីពីវិធីសាស្ត្រនៃការទទួលពាក្យបណ្ដឹង ការអង្កេត ស្រាវជ្រាវ និងសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ (៦)សេចក្ដីណែនាំស្ដីពីវិធីសាស្ត្រនៃការធ្វើអធិការកិច្ចលើការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា
- ធ្វើការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយការងារអធិការកិច្ចពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈចំនួន១១វគ្គ (ឆ្នាំ២០២៣ ចំនួន១០វគ្គ និងត្រីមាសទី១ ឆ្នាំ២០២៤ ចំនួន១វគ្គ) រួមមាន៖ (១) ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋបាលរាជធានីភ្នំពេញ ខេត្តកំពត ខេត្តព្រៃវែង និងខេត្តក្រចេះ ចំនួន៥វគ្គ (២)ផ្ទៃក្នុងអគ្គាធិការដ្ឋានដើម្បីអភិវឌ្ឍសមត្ថភាពនិងចែករំលែកបទពិសោធន៍ដល់មន្ត្រីរាជការ ចំនួន៦វគ្គ
- ចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើការប្រើប្រាស់ទីប្រឹក្សា ជំនួយការ និងក្រុមប្រឹក្សា ជំនួយការរបស់ក្រសួងមុខងារសាធារណៈ ដែលកំពុងបម្រើការងារនៅខេត្តក្រចេះ ចំនួន១លើក
- ពិនិត្យស្រាវជ្រាវ សម្រុះសម្រួល និងតាមដានករណីបណ្ដឹងតវ៉ាពាក់ព័ន្ធនឹងវិវាទមុខងារសាធារណៈ របស់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន១៥ករណី រួមមាន៖ (១)ឆ្នាំ២០២៣ ចំនួន១១ករណី ក្នុងនោះបានសម្រុះសម្រួលដោះស្រាយបញ្ចប់វិវាទផ្ទៃក្នុងអង្គភាពចំនួន៨ករណី (ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខណ្ឌ៥ករណី ការស្នើសុំចូលនិវត្តន៍មុនកាលកំណត់១ករណី ការអនុវត្តទណ្ឌកម្មខាងវិន័យគឺការសម្រួលភារកិច្ចពីប្រធានអង្គភាពច្រកចេញចូលតែមួយទៅជាមន្ត្រី១ករណី ការប្ដឹងតវ៉ាភាពមិនប្រក្រតីរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ១ករណី) (២)ត្រីមាសទី១ ឆ្នាំ២០២៤ ចំនួន៤ករណី ក្នុងនោះបានបង្វែរសំណុំរឿងទៅឱ្យអង្គភាពសាមី ដើម្បីដោះស្រាយ៣ករណី និងកំពុងបន្តពិនិត្យ ស្រាវជ្រាវ តាមដាន១ករណី
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គាធិការដ្ឋានបានចូលរួមវគ្គបណ្ដុះបណ្ដាល និងកម្មវិធីផ្សេងៗ ចំនួន ១៩លើក។

## ១.២. ការកែទម្រង់រដ្ឋបាលសាធារណៈ

ក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចការនេះ សម្រេចបានលទ្ធផលដូចខាងក្រោម៖

### ១.២.១. ការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ

**វិធានការគន្លឹះទី១ - ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី**

- ដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិ សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល តាមរយៈអនុក្រឹត្យស្ដីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល
- អនុវត្តការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ/សង្កាត់ សម្រាប់ក្របខណ្ឌឆ្នាំ២០២៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ២៥០ នាក់ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣
- អនុវត្តការប្រឡងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ក្របខណ្ឌឆ្នាំ២០២៣ ចំនួន ១០០ នាក់ សម្រាប់ខេត្តគោលដៅ ចំនួន ២១ កាលពីថ្ងៃទី២៨ ដល់ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤
- អនុវត្តការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ក្របខណ្ឌឆ្នាំ២០២៣ ចំនួន ៥២ នាក់ កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤

- អនុវត្តការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសាធារណការនិង ដឹកជញ្ជូន សម្រាប់ក្របខណ្ឌឆ្នាំ២០២៣ ចំនួន ៩៩ នាក់ កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤
- អនុវត្តការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌអង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ក្របខណ្ឌឆ្នាំ២០២៣ ចំនួន ៣៣ នាក់ កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៤
- រៀបចំផែនការអនុវត្តការប្រឡងប្រជែងផ្សេងទៀតជាបន្តបន្ទាប់ក្នុងឆ្នាំ២០២៤ តាមគោលការណ៍សម្រេចរបស់ ប្រមុខរាជរដ្ឋាភិបាល។

**វិធានការគន្លឹះទី២ - ការលើកម្ពស់ប្រសិទ្ធភាពការងារ**

- រៀបចំសេចក្តីព្រាងគម្រោង ចំនួន ៣ គឺៈ (១)ការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ ក្រសួង ស្ថាប័នថ្នាក់ជាតិ (២)ការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័នថ្នាក់ជាតិ និង (៣) ក្រមសីលធម៌មន្ត្រីរាជការស៊ីវិល
- រៀបចំសេចក្តីព្រាងតារាងមុខងារស្នូល ចំនួន ២ គឺៈ (១)តារាងស្តង់ដាមុខងារស្នូល បង្ហាញអំពីមុខងារស្នូល មុខងាររង រចនាសម្ព័ន្ធ ជំនាញ សមត្ថភាព និងលទ្ធផលរំពឹងទុក និង(២) តារាងមុខងារស្នូល បង្ហាញអំពីមុខងារ ស្នូល មុខងាររង រចនាសម្ព័ន្ធបច្ចុប្បន្ន នវានុវត្តន៍ និងបញ្ហាប្រឈម
- រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល
- រៀបចំសេចក្តីព្រាងឯកសារជំនួយស្មារតីស្តីពីការរៀបចំប្រព័ន្ធគ្រប់គ្រងវត្តមាន
- ដាក់ឱ្យអនុវត្តសេចក្តីណែនាំអន្តរក្រសួងស្តីពីការបើកផ្តល់បៀវត្ស និងការគ្រប់គ្រងការផ្ទេរបុគ្គលិកអប់រំទៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ (ប្រមាណ ៦ ម៉ឺន នាក់ រួមទាំងមន្ត្រីជាប់កិច្ចសន្យា) និងធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីអប់រំ ជាក់ស្តែង
- រៀបចំសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពី ការតែងតាំងនាយកនិងនាយករងសាលាបឋមសិក្សា និង សាលាមធ្យមសិក្សា និងកំពុងបន្តពិភាក្សា
- រៀបចំការអនុវត្តខ្លឹមសារនៃព្រះរាជក្រឹត្យពាក់ព័ន្ធទីប្រឹក្សានិងជំនួយការ ដើម្បីពង្រឹងការងារមន្ត្រីរាជការ និង ការបើកផ្តល់បៀវត្ស។

**វិធានការគន្លឹះទី៣ - ការកែលម្អប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម**

- រៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពីប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម

## ខ.២.២. ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ

### ខ.២.២.១. ការងារបរិវត្តកម្ម និងនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ

- ប្រមូលចងក្រងកម្រងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ បានចំនួន៥ក្រសួង ស្ថាប័នគឺៈ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម និង ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- ប្រមូលចងក្រងឯកសារគោលនយោបាយសេវាសាធារណៈ និងឯកសារទស្សនទាននៃការបង្កើតការិយាល័យ ច្រកចេញចូលតែមួយ។

### ខ.២.២.២. ការងារលើកកម្ពស់ឧត្តមភាពសេវាសាធារណៈ

- រៀបចំពិធីប្រកាសជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈ គំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤
- រៀបចំសិក្ខាសាលាចែករំលែកបទពិសោធនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាព ផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២៣ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤

- រៀបចំប្រកាសអន្តរក្រសួងស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាព ផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងប្រកាសអន្តរក្រសួងស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាព ផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤ ដែលផ្តោតលើវិទ្យាល័យនិងសាលាមត្តេយ្យសិក្សាសម្រាប់វិស័យអប់រំ និងមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល
- អនុវត្តការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុង វិស័យអប់រំនិងវិស័យសុខាភិបាល នៅដំណាក់កាលវាយតម្លៃជ្រើសសម្រាំងបេក្ខភាពជ័យលាភី និងចុះវាយតម្លៃនៅទីតាំងជាក់ស្តែងរបស់បេក្ខភាពជ័យលាភីអនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាពគំរូ និងកំណត់វិធានការអនុវត្តបន្ត
- រៀបចំគម្រោងសិក្សាអំពីទស្សនាទាន និងបទពិសោធនៃការរៀបចំនិងការអនុវត្តនិយាមប្រតិបត្តិនៃអង្គភាព និងមន្ត្រីផ្តល់សេវាជួរមុខ
- រៀបចំគម្រោងសិក្សាអំពីទស្សនាទាននៃការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាធារណៈគំរូ

**ខ.២.២.៣. ការងារគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស**

- រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស រួមមាន៖ (១)លក្ខន្តិកៈដោយឡែកនៃអង្គអប់រំនិងសុខាភិបាល (២)ការដំឡើងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងប្រាក់ឧបត្ថម្ភក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ (៣)ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នថ្នាក់ជាតិ (៤)ការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល នគរបាលជាតិ មន្ត្រីពន្ធនាគារ យោធិននៃកងយោធពលខេមរភូមិន្ទ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានសិក្សា ត្រួតពិនិត្យ កែលម្អ និងបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការនៃការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ.២.២.៤. ការងារកសាងសមត្ថភាពមន្ត្រី**

- រៀបចំសេចក្តីព្រាងគម្រោងចំនួន២ រួមមាន៖ ទី១-គម្រោងស្តីពីការបណ្តុះបណ្តាលសម្រាប់កម្រិតអគ្គនាយក និងអភិបាលនៃគណៈអភិបាលរាជធានីខេត្ត និងទី២-គម្រោងស្តីពីការបណ្តុះបណ្តាលកម្រិតប្រធាននាយកដ្ឋានគ្រប់គ្រងធនធានមនុស្ស និងនាយកទីចាត់ការធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្ត។

**ខ.២.២.៥. ការរៀបចំនិងធ្វើបច្ចុប្បន្នភាពកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ**

សេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២៤-២០៣៥ ត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាព ដោយអនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងឯកសារផែនការយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ជាពិសេសស្របតាមវិធានការគន្លឹះទាំងបីនៃការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលបានដាក់ចេញរួមមាន៖ ១-ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ២-ការលើកកម្ពស់ប្រសិទ្ធភាពការងារ ៣-ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ។

**ខ.២.២.៦. ការរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ការកែទម្រង់រដ្ឋបាលសាធារណៈ**

បានរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ការកែទម្រង់រដ្ឋបាលសាធារណៈ ដូចខាងក្រោម៖

- ព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា (គ.វ.រ.)
- ព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស.)
- អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (អ.គ.ក.ស.)

- អនុក្រឹត្យ ស្តីពីតួនាទីភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា
- សេចក្តីសម្រេច ស្តីពីការតែងតាំងនិងបន្ថែមសមាសភាពគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិនិងក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- សេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពអនុគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- សេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពបន្ថែមនៃអនុគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- សេចក្តីសម្រេច ស្តីពីការតែងតាំងនិងបន្ថែមសមាសភាពគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សេចក្តីសម្រេច ស្តីពីការតែងតាំងនិងបន្ថែម សមាសភាពក្រុមការងារបច្ចេកទេស នៃអនុគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- សេចក្តីសម្រេចស្តីពីការតែងតាំងនិងបន្ថែម សមាសភាពអនុគណៈកម្មាធិការ នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួងមុខងារសាធារណៈ
- សេចក្តីសម្រេច ស្តីពីការកំណត់សមាសភាព និងតួនាទី ភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន និងសេចក្តីសម្រេចស្តីពីការកំណត់សមាសភាព និងតួនាទី ភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃរដ្ឋបាលរាជធានី ខេត្ត
- សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យអប់រំ
- សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីក្នុងវិស័យសុខាភិបាល។

### ខ.២.២.៧. ការងារសម្របសម្រួលការងារកែទម្រង់អន្តរវិស័យ

- រៀបចំផែនការសុខដុមនីយកម្មការកែទម្រង់ ៣បូក១ សម្រាប់ឆ្នាំ២០២៤
- រៀបចំផែនការសកម្មភាព និងសូចនាករនៃក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ច ២០២២-២០៣៥ ដែលទទួលបន្ទុកដោយក្រសួងមុខងារសាធារណៈ
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ ៣បូក១ នៃឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣បូក១ សម្រាប់ឆ្នាំ២០២៣ ដែលទទួលបន្ទុកដោយការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងមុខងារសាធារណៈ
- រៀបចំតារាងបញ្ជីឯកសារគោលនយោបាយ រួមមាន៖ (១)ឯកសារពាក់ព័ន្ធនឹងភាពជាដៃគូនិងយុទ្ធសាស្ត្រទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងយន្តការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ (២)លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារកែទម្រង់ វិស័យអប់រំនិងសុខាភិបាល
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយតំណាងធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា ដើម្បីគាំទ្រដល់ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

#### ខ.២.២.៨. ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រដល់វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងក្របខណ្ឌកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ស្នើដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីរៀបចំរបាយការណ៍ស្ដីពីការអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្នុងស្ថានភាពបច្ចុប្បន្ន ដើម្បីជាមូលដ្ឋានក្នុងការសិក្សារៀបចំពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការងារ
- ស្នើដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីរៀបចំរបាយការណ៍ស្ដីពីការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្នុងស្ថានភាពបច្ចុប្បន្ន ដើម្បីជាមូលដ្ឋានក្នុងការសិក្សារៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រផ្អែកលើសមិទ្ធកម្ម។

## ខ.៣. ការគាំទ្រកិច្ចការមុខងារសាធារណៈ

### ខ.៣.១. កិច្ចការរដ្ឋបាល

កិច្ចការរដ្ឋបាល សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- ក្រសួងបានទទួលលិខិតចូល ចំនួន ១១,២៩៨លិខិត និងលិខិតចេញ ចំនួន ៦,៩២៩លិខិត ក្នុងនោះលិខិតបញ្ជាបេសកកម្ម និងឧទ្ទេសនាម ចំនួន ៨៦៤លិខិត
- រៀបចំកិច្ចប្រជុំ សរុបចំនួន ៦៦៤លើក (១)ផ្ទៃក្នុងក្រសួង ចំនួន ១៨៧លើក (២)អន្តរក្រសួង ចំនួន ១៣១លើក (៣)អន្តរក្រសួងចង្អៀត ចំនួន ២៤លើក (៤)អគ្គនាយកដ្ឋាន/អគ្គាធិការ ចំនួន ៣៧លើក (៥)នាយកដ្ឋាន ចំនួន ១៣២លើក (៦)ក្រុមការងារ ចំនួន ៩៧លើក (៧)អន្តរជាតិ ចំនួន១៥លើក (៨)វគ្គបណ្ដុះបណ្ដាល ចំនួន ១៥លើក និង(៩)ផ្សេងៗ ចំនួន ១៦លើក និងមានសមាជិកចូលរួម សរុបចំនួន ២៥,៣៩០នាក់។

### ខ.៣.២. កិច្ចការធនធានមនុស្ស

កិច្ចការធនធានមនុស្ស សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ ក្រសួងមុខងារសាធារណៈមានមន្ត្រីរាជការ សរុបចំនួន ១,៣៦៣នាក់/ស្ត្រី ៤៦៥នាក់ (ទីស្ដីការក្រសួង ចំនួន ៨៥៨នាក់/ស្ត្រី ២៦៩នាក់ និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ចំនួន ៥០៥នាក់/ស្ត្រី ១៩៦នាក់) និងមន្ត្រីជាប់កិច្ចសន្យា សរុបចំនួន ៣៦៤នាក់/ស្ត្រី ១៨៣ នាក់ (ទីស្ដីការក្រសួង ចំនួន ២៤៥ នាក់/ស្ត្រី ១២១ នាក់ និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ចំនួន ១១៩ នាក់/ស្ត្រី ៦២ នាក់)។
- ស្ថានភាពរដ្ឋបាលមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈមានបង្ហាញជូនក្នុងតារាង៤
- បញ្ជូនមន្ត្រីចូលរួមវគ្គបណ្ដុះបណ្ដាលនៅក្នុងប្រទេស សរុបចំនួន ៥៣៦នាក់/ស្ត្រី ១៤៥នាក់
- បញ្ជូនមន្ត្រីចូលរួមវគ្គបណ្ដុះបណ្ដាលក្រៅប្រទេស សរុបចំនួន ៤៧នាក់/ស្ត្រី ១៣នាក់
- ផ្សព្វផ្សាយសេចក្ដីជូនដំណឹងស្ដីពីការផ្ដល់អាហារូបករណ៍ សម្រាប់ថ្នាក់បណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ និងវគ្គបណ្ដុះបណ្ដាលខ្លី ចំនួន ៩លើក ។
- បញ្ចប់ការដាក់ពង្រាយមន្ត្រី ការរៀបចំតែងតាំងនិងប្រគល់ភារកិច្ចជូនមន្ត្រីរាជការថ្នាក់ជាតិស្របតាមរចនាសម្ព័ន្ធថ្មីរបស់ក្រសួងមុខងារសាធារណៈ ដោយបានរៀបចំពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធាណៈនាថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤។ សម្រាប់ថ្នាក់ក្រោមជាតិ នាយកដ្ឋានធនធានមនុស្សបានស្នើផ្ទេរមន្ត្រីជាប់កិច្ចសន្យាពីមន្ទីរមុខងារសាធារណៈខេត្តផ្សេងជូនមន្ទីរមុខងារសាធារណៈខេត្តស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ ដែលមានចំនួនមន្ត្រីតិចជាងគេ
- ពង្រឹងកិច្ចការគ្រប់គ្រងវត្តមានធ្វើការរបស់មន្ត្រីរាជការ

### ខ.៣.៣. កិច្ចការហិរញ្ញវត្ថុ

កិច្ចការហិរញ្ញវត្ថុ សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- លិខិតប្រកាសអាណាប័កផ្ទេរសិទ្ធិ រាជធានីខេត្ត និងសាលាភូមិន្ទរដ្ឋបាល ចំនួន ២៦លិខិត
- ទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ទីស្តីការក្រសួង និងសាលាភូមិន្ទរដ្ឋបាល
- ធ្វើបច្ចុប្បន្នភាពស្ថិតិដីរបស់មន្ទីរមុខងារសាធារណៈរាជធានី-ខេត្តទាំង២៥
- រៀបចំប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង និងសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ទីស្តីការក្រសួង

**តារាង៥. ស្ថានភាពរដ្ឋបាលមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ**

| ល.រ | បរិយាយ | ចំនួន | ស្ត្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | សុំច្បាប់ឈប់សម្រាករបស់មន្ត្រីរាជការ | ១៧២ | ៥៥ | |
| ២ | ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ៤៣៨ | ១០២ | |
| ៣ | តែងតាំងជំនួយការ | ២១ | ១៤ | |
| ៤ | ព្រះរាជក្រឹត្យ អនុក្រឹត្យបញ្ចប់មុខតំណែងមន្ត្រីរាជការ | ៣ | ១ | |
| ៥ | និយ័តកម្ម ប្តូរប្រភេទក្របខណ្ឌ ដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការដោយព្រះរាជក្រឹត្យ | ៧៦ | ៣២ | |
| ៦ | និយ័តកម្ម ប្តូរប្រភេទក្របខណ្ឌ ដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការដោយអនុក្រឹត្យ | ៣០ | ២ | |
| ៧ | ការដំឡើងថ្នាក់តាមវេនអតីតភាពការងារឆ្នាំ២០២៣ | ៤២៧ | ១៥៤ | |
| ៨ | ការដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រឆ្នាំ២០២២ | ៧១ | ១៨ | |
| ៩ | ប្រកាសស្តីពីការសម្រួលភារកិច្ចមន្ត្រីរាជការ | ៥ | ១ | |
| ១០ | លិខិតបង្គាប់ការ | ២ | ០ | |
| ១១ | បំពេញសលាកបត្រមន្ត្រីរាជការក្របខណ្ឌឆ្នាំ២០២៣ | ១០០ | ៣៧ | |
| ១២ | សុំគោលការណ៍ស្តីពីការតែងតាំងមន្ត្រីរាជការមន្ទីរមុខងារសាធារណៈខេត្តរតនគិរី និងខេត្តកំពត | ៦ | ០ | |
| ១៣ | មន្ត្រីផ្ទេរចូល | ២៥ | ៧ | |
| ១៤ | មន្ត្រីផ្ទេរចេញ | ២២ | ៣ | |
| ១៥ | ប្រកាសស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ | ៣ | ១ | |
| ១៦ | ប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតក្រៅក្របខណ្ឌដើម | ៣ | ០ | |
| ១៧ | បញ្ចូលកូន | ៤២ | ០ | |
| ១៨ | បញ្ចូលប្រពន្ធ | ១៩ | ១៩ | |
| ១៩ | ចូលបម្រើការងារវិញ | ៦ | ២ | |
| ២០ | លុបឈ្មោះមន្ត្រី | ២ | ១ | |
| ២១ | ដាក់មន្ត្រីឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ១២ | ៤ | |
| ២២ | តាំងស៊ប់មន្ត្រីរាជការ | ២០ | ១ | |
| ២៣ | ចូលនិវត្តន៍ | ៥ | ០ | |
| ២៤ | បញ្ជាក់វិញ្ញាបនបត្ររដ្ឋបាល/បៀវត្ស និងផ្តាច់ប្រាក់បៀវត្សមន្ត្រីរាជការ | ១៧៦ | ៤០ | |
| | **សរុប** | **១,៦៨៦** | **៤៩៤** | |

- រៀបចំតារាងប្រៀបធៀបកើនឡើង ថយចុះ ទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២២ របស់ទីស្តីការក្រសួង និងបានបញ្ជូនទៅអគ្គនាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចរាល់
- រៀបចំសំណើសុំស្លាកលេខរដ្ឋ និងប័ណ្ណសម្គាល់ទោចក្រយានយន្ត ជូនដល់ទីស្តីការ និងមន្ទីរមុខងារសាធារណៈរាជធានីខេត្ត ចំនួន ១៥ ដែលមានចំនួនសរុប ២៧គ្រឿង
- ធ្វើការបូកបាយការណ៍ចំណាយថវិកាប្រចាំឆ្នាំ២០២២ ដើម្បីរៀបចំរបាយការណ៍សម្រេចទូទាត់ សម្រាប់ការគ្រប់គ្រងថវិការដ្ឋ ឆ្នាំ២០២២ នៅរដ្ឋបាលកណ្តាល និងមន្ទីររាជធានី-ខេត្ត
- រៀបចំប្រកាស ស្តីពីការកែសម្រួលសមាសភាពក្រុមលទ្ធកម្មរបស់អង្គភាពថវិកាមន្ទីរមុខងារសាធារណៈចំនួន ៦ គឺ ខេត្តរតនគិរី ខេត្តកំពត ខេត្តកំពង់ចាម ខេត្តកោះកុង ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ
- ពិនិត្យ និងតាមដានការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ របស់អង្គភាពថវិកាសាលាភូមិន្ទរដ្ឋបាល និងមន្ទីរមុខងារសាធារណៈទាំង២៥ រាជធានី ខេត្ត។

**ខ.៣.៤. កិច្ចការផ្សព្វផ្សាយ និងទំនាក់ទំនង**

កិច្ចការផ្សព្វផ្សាយ និងទំនាក់ទំនង សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- សម្របសម្រួលការផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ និងកម្មវិធីផ្សេងៗរបស់ក្រសួង នៅតាមបណ្តាអង្គភាពសារព័ត៌មាន ចំនួន៤១៧អង្គភាព និងបានរៀបចំខ្លឹមសារ ចំនួន៦៦៣មាតិកា (ក្នុងនោះបានផ្សព្វផ្សាយសកម្មភាព **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** អញ្ជើញចូលរួមកម្មវិធីផ្សេងៗរបស់រាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំប្រទេស នៅលើគេហទំព័រ និងហ្វេសប៊ុកក្រសួង សរុបចំនួន១១០លើក)
- រៀបចំនិងផ្សព្វផ្សាយលិខិតផ្សេងៗចំនួន១៣៩លើក (ក្នុងនោះសារលិខិតថ្វាយព្រះពរ អបអរសាទរព្រះមហាក្សត្រ និងព្រះមហាក្សត្រី និងបានជូនពរឥស្សរជនជាន់ខ្ពស់ចំនួន១១៣លើក និងសារលិខិតរំលែកមរណទុក្ខ ចំនួន ២៦លើក)
- លទ្ធផលនៃការផ្សព្វផ្សាយព័ត៌មានតាមរយៈមធ្យោបាយផ្សាយផ្លូវការរបស់ក្រសួង "ក្រសួងមុខងារសាធារណៈ" និងយន្តការផ្សាយបន្ថែម "ព័ត៌មានមុខងារសាធារណៈ" មានដូចក្នុងតារាង៥ខាងក្រោម
- រៀបចំការផ្សព្វផ្សាយលើគ្រប់បណ្តាញផ្សាយក្រសួងទាំងអស់ចំនួន៤,២០៥ដង ក្នុងនោះលើបណ្តាញសង្គមផ្លូវការរបស់ក្រសួង (ក្រសួងមុខងារសាធារណៈ) បានចំនួន៣,៣៦១ ដង និងបណ្តាញថ្មី (ព័ត៌មានមុខងារសាធារណៈ) បានចំនួន៨៤៤ ដង
- រៀបចំមាតិកាព័ត៌មាន និងមាតិកាពាក់ព័ន្ធជាប្រចាំធ្វើឱ្យគ្រប់បណ្តាញផ្សព្វផ្សាយរបស់ក្រសួងមានចំនួនអ្នកភ្ជាប់កើនឡើងគួរឱ្យកត់សម្គាល់ និងសាធារណជនបានចូលទស្សនា រួមយោបល់ និងចែករំលែកព័ត៌មានបន្តមានច្រើនសន្ធឹកសន្ធាប់ ក្នុងនោះបណ្តាញដ៏មានប្រជាប្រិយរបស់ក្រសួង គឺ "ទំព័រហ្វេសប៊ុក ផ្លូវការរបស់ក្រសួង" ដែលបានផ្សាយចំនួន ១,០០៣ដង ដោយមានការចុច (Likes) ចំនួន៧៧,៨៩៤ដង ការចូលទៅផ្តល់យោបល់ (Comments) ចំនួន៦,២៦៥ និងការចែករំលែក (Shares) ចំនួន២២,០៦៣៥ដង។ រីឯការផ្សាយព័ត៌មាននានានៅលើទំព័រហ្វេសប៊ុកថ្មី (ព័ត៌មានមុខងារសាធារណៈ) បានចំនួន ២៩៦ដង ដោយទទួលបានការចុច (Likes) ចំនួន៨,៦៤៦ដង ការចូលទៅផ្តល់យោបល់ (Comments) ចំនួន១,៤១៦ និងការចែករំលែក (Shares) ចំនួន១,១៧៧ដង
- តាមដាន និងសង្ខេបព័ត៌មានប្រចាំថ្ងៃពីស្ថាប័នសារព័ត៌មាននានាពាក់ព័ន្ធនឹងការងារមុខងារសាធារណៈ រដ្ឋបាលសាធារណៈ និងរាជរដ្ឋាភិបាល រួមទាំងព្រឹត្តិការណ៍ជាតិនិងអន្តរជាតិ សរុបចំនួន ២,៦៥១មាតិការឿង
- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការជ្រើសរើសក្របខណ្ឌមន្ត្រីរាជការ និងផលិតវីដេអូពីរបៀបចុះឈ្មោះប្រឡង ចំនួន៥លើក៖ ១.ជ្រើសរើសក្របខណ្ឌមន្ត្រីកសិកម្មឃុំចំនួន ២៥០នាក់ ចំនួន៣លើក ២.ជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា និង៣.ជ្រើសរើសគ្រូអនុវិទ្យាល័យ

តារាង៦. លទ្ធផលនៃការផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្តាញសង្គម

| ល.រ | ឈ្មោះកម្មវិធី | ចំនួន Post | ចំនួនអ្នកភ្ជាប់សរុប (Subscriber, Follower) | ចំនួនអ្នកភ្ជាប់ថ្មី (New Subscriber, Follower) |
|---|---|---|---|---|
| បណ្តាញសង្គមផ្លូវការរបស់ក្រសួង (ក្រសួងមុខងារសាធារណៈ) | | | | |
| ១ | គេហទំព័រ (Website) | 1.005 | 256.125 | N.A (កំពុងជួសជុល) |
| ២ | ទំព័រហ្វេសប៊ុក (Facebook Page) | 1.003 | 269.683 | 68.776 |
| ៣ | ឆាណែលតេឡេក្រាម (Telegram Channel) | 1.020 | 11.983 | 11.983 |
| ៤ | Tik Tok | 133 | 695 | 695 |
| ៥ | Instagram | 142 | 229 | 229 |
| ៦ | YouTube | 58 | 1.410 | 501 |
| **សរុប** | | **3.361** | **540.125** | **82.184** |
| បណ្តាញសង្គមរបស់ក្រសួងថ្មី (ព័ត៌មានមុខងារសាធារណៈ) | | | | |
| ១ | ទំព័រហ្វេសប៊ុក (Facebook Page) | 296 | 2,914 | 2.914 |
| ២ | តេឡេក្រាម (Telegram Channel) | 267 | 1,311 | 1.311 |
| ៣ | Tik Tok | 141 | 807 | 807 |
| ៤ | Instagram | 183 | 37 | 37 |
| ៥ | YouTube | - | - | - |
| **សរុប** | | **844** | **5069** | **5069** |
| **សរុបរួម** | | **4.205** | **545.194** | **87.253** |

- សម្របសម្រួលរៀបចំសន្និសីទសារព័ត៌មាន និងផលិតវីដេអូ ពាក់ព័ន្ធការងារប្រឡងជ្រើសរើសមន្ត្រីរាជការ ចំនួន៥ រួមមាន៖ ១.ដំណើរការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌក្រសួងកសិកម្មឃុំ ចំនួន២៥០នាក់ ២.អង្គភាពសេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៣ សម្រាប់ពិធីប្រកាសជ័យលាភី ៣.សកម្មភាពនៃដំណើរការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន ឯកទេសអប់រំកាយ និងកីឡា ៤.ស្តាប់ចំណាប់អារម្មណ៍អ្នកពាក់ព័ន្ធជុំវិញការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលដោយឈរលើគោលការណ៍គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព និង៥.ស្តីពីអង្គភាពសាធារណៈគំរូរួចរាល់សម្រាប់ពិធីប្រកាសជ័យលាភីថ្ងៃទី២១ និង២២ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**
- ផលិតវីដេអូ ចំនួន៣១ កាត់តឃ្លីបវីដេអូពាក់ព័ន្ធនិងប្រសាសន៍ សម្តេចបវរធិបតីនាយករដ្ឋមន្ត្រី ចំនួន០៤ ផ្សព្វផ្សាយវីដេអូ ចំនួន៥៤លើក និងជ្រើសរើស រក្សាទុករូបភាព វីដេអូក្នុងបណ្ណសារបាន ចំនួន៣៥០លើក រៀបចំរចនាផូស្ទ័រ ចំនួន១១០ (គិតត្រឹមឆ្នាំ២០២៣ ដល់ ០៥ មីនា ឆ្នាំ២០២៤) ពាក់ព័ន្ធនឹងកិច្ចការកំណែទម្រង់ការប្រឡងជ្រើសរើសក្របខណ្ឌមន្ត្រី ដែលបង្ហាញពីការជ្រើសរើសឈរលើគោលការណ៍គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព។

### ខ.៣.៥. កិច្ចការនីតិកម្ម

កិច្ចការនីតិកម្ម សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- លទ្ធផលការងារស្នូលសំខាន់ៗសម្រេចបានចំនួន ៣១ រួមមាន៖ ព្រះរាជក្រឹត្យចំនួន ២ អនុក្រឹត្យចំនួន ១៤ ប្រកាសចំនួន ៨ និងសេចក្តីសម្រេចចំនួន ៣
- រៀបចំលិខិតឆ្លើយតបទៅនឹងសំណើសុំកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង និងសំណើសុំផ្សេងៗរបស់ក្រសួង-ស្ថាប័ន ចំនួន ២៦លិខិត រួមមាន៖ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចំនួន ២លិខិត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន២លិខិត ក្រសួងអប់រំ យុវជន និងកីឡា ចំនួន៥លិខិត ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ២លិខិត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ១លិខិត ក្រសួងសុខាភិបាល ចំនួន ៩លិខិត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១លិខិត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចំនួន ១លិខិត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ២លិខិត រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ចំនួន ១លិខិត។
- លិខិតបទដ្ឋានគតិយុត្ត តាមប្រភេទ ដែលសម្រេចបានក្នុងឆ្នាំ២០២៣ មានក្នុងតារាង៦ខាងក្រោម

**តារាង៧. លិខិតបទដ្ឋានគតិយុត្ត តាមប្រភេទ ដែលសម្រេចបានក្នុងឆ្នាំ២០២៣**

| ល.រ | ចំណងជើង | លេខលិខិត និងកាលបរិច្ឆេទ |
|---|---|---|
| **១.ព្រះរាជក្រឹត្យ ចំនួន ០២** | | |
| ១ | ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល | នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣ |
| ២ | ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ |
| **២.អនុក្រឹត្យ ចំនួន ១៤** | | |
| ១ | ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល | លេខ០៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ |
| ២ | ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារយោធិននៃកងយោធពលខេមរភូមិន្ទ | លេខ០៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ |
| ៣ | ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីនគរបាលជាតិកម្ពុជា | លេខ០៦អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ២០២៣ |
| ៤ | ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ | ០៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ២០២៣ |
| ៥ | ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យ ប្រជាពលរដ្ឋ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | លេខ០៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ |
| ៦ | ស្តីពីការដំឡើងប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យា | លេខ០៩ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ |
| ៧ | ស្តីពីការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារប្រចាំខែ របស់ឧបការីកែម្រិត ទី៤ ទី៥ និងទី៦ នៃអង្គភាពប្រឆាំងអំពើពុករលួយ | លេខ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ |
| ៨ | ស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន | លេខ៤៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២៣ |

| | | |
|---|---|---|
| ៩ | ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៦ និងពិធីបុណ្យភ្ជុំបិណ្ឌឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧ | លេខ៧១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ |
| ១០ | ស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | លេខ៧៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ |
| ១១ | ស្តីពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារ សាធារណៈ ក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការ កែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា | លេខ៣០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ |
| ១២ | ស្តីពីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ | លេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ |
| ១៣ | ស្តីពីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | លេខលេខ៣២៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ |
| ១៤ | ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល | លេខ៣២៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ |
| | **៣.ប្រកាស ចំនួន ០៨** | |
| ១ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងលេខាធិការដ្ឋានរបស់អគ្គលេខាធិការដ្ឋានក្រសួងមុខងារសាធារណៈ | លេខ៦០២៥/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| ២ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងលេខាធិការដ្ឋានរបស់អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ | លេខ៦០២៦/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| ៣ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងលេខាធិការដ្ឋាន របស់អគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមឌីជីថល នៃក្រសួងមុខងារសាធារណៈ | លេខ៦០២៧/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| ៤ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងលេខាធិការដ្ឋាន របស់អគ្គាធិការដ្ឋានក្រសួងមុខងារសាធារណៈ | លេខ៦០២៨/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| ៥ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន របស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | លេខ៦០២៩/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| ៦ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងលេខាធិការដ្ឋាន របស់សាលាភូមិន្ទរដ្ឋបាល នៃក្រសួងមុខងារសាធារណៈ | លេខ៦០៣០/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| ៧ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងអង្គភាពរបស់អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ | លេខ៦០៣១/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| ៨ | ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងមុខងារសាធារណៈ | លេខ៦០៣២/២៣ មស.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ |
| | **៤.សេចក្តីសម្រេចចំនួន ០៣** | |
| ១ | ស្តីពីការតែងតាំងសមាសភាព គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា | លេខ១០៧/២៣ មស.សសរ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ |
| ២ | ស្តីពីការបង្កើតអនុគណៈ កម្មាធិការប្រតិបត្តិ និងក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការ កែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា | លេខ១២៥/២៣ មស.សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ |

| | | |
|---|---|---|
| ៣ | ស្តីពីការតែងតាំងសមាសភាព អនុគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការ កែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា | លេខ១២៥/២៣ មស.សសរ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ |

### ខ.៣.៦. កិច្ចការផែនការ

កិច្ចការផែនការ សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- រៀបចំបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ សម្រាប់រៀបចំសន្និបាត និងសម្របសម្រួលក្នុងការរៀបចំ កម្មវិធីសន្និបាត សមាសភាពចូលរួមសន្និបាត លិខិតអញ្ជើញ ប្លង់អង្គុយ និងពិនិត្យទីតាំងសន្និបាត
- រៀបចំបូកសរុប របាយការណ៍វឌ្ឍនភាពការងារនិងលើកការងារបន្ត ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ២០២៣ ជូនទីស្តីការគណៈរដ្ឋមន្ត្រី តាមកាលកំណត់
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពការងារ និងទិសដៅអនុវត្តបន្តរបស់ក្រសួងមុខងារសាធារណៈ ក្នុងការងារអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ក្នុងជំនួបពិភាក្សាការងារជាមួយ គណៈកម្មការទី៤ នៃរដ្ឋសភា
- ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤(បច្ចុប្បន្នភាព) ត្រូវបានសម្រេចនិងផ្សព្វផ្សាយជូនអង្គភាពក្រោមឱវាទក្រសួងមុខងារសាធារណៈទាំងអស់ ដើម្បីយកទៅអនុវត្ត
- ប្រមូលនិងបូកសរុប សេចក្តីព្រាងបឋមផែនការប្រតិបត្តិឆ្នាំ២០២៥ (AOP-2025) របស់ក្រសួមុខងារសាធារណៈ
- រៀបចំ និងបញ្ជូនលិខិតជូនក្រសួងផែនការ ចំនួន៩លើកសំខាន់ៗ រួមមាន៖ (១)របាយការណ៍ពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(ផ.យ.អ.ជ) ២០១៩-២០២៣ (២)ការរៀបចំធាតុចូលសម្រាប់របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០២៣ (៣)របាយការណ៍វឌ្ឍនភាពឆ្នាំ២០២២ នៃផែនការសកម្មភាព២០២២-២០២៤ (៤)ផ្តល់ធាតុចូលលើ "សំណើសុំធាតុចូលសម្រាប់ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រកម្ពុជា២០២៣-២០៣០ ដើម្បីតាមដានការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍" (៥)ផ្តល់ធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ) ២០២៤-២០២៨ (៦)រៀបចំគម្រោងសម្រាប់ដាក់ចូលកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២៥-២០២៧ (៧)ករណីការធ្វើបច្ចុប្បន្នភាពសមាជិកភាព នៃក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ (៨)ករណីសំណើចាត់រដ្ឋលេខាធិការ១រូប ជាសមាជិកគណៈកម្មាធិការពិសេស តាមដានការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិ ស្តីពីប្រជាជន និងអភិវឌ្ឍន៍ និងមន្ត្រីជាន់ខ្ពស់ ១រូប ជាសមាជិកគណៈកម្មការអន្តរក្រសួង និង(៩)ករណីសំណើសុំចាត់តាំងមន្ត្រីជាន់ខ្ពស់ចំនួន០១រូប ថ្នាក់អគ្គនាយករង ឬប្រធាននាយកដ្ឋានចូលរួមជាសមាជិកក្រុមការងារអន្តរក្រសួងសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិប្រជាជន២០១៦-២០៣០។

## ខ.៤. កិច្ចការសវនកម្មផ្ទៃក្នុង

កិច្ចការសវនកម្មផ្ទៃក្នុង សម្រេចបានលទ្ធផល ដូចខាងក្រោម៖

- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២៣ និងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ និងប្រចាំត្រីមាសនីមួយៗ
- ចុះប្រមូលព័ត៌មាន និងសិក្សាហានិភ័យ ព្រមទាំងរៀបចំរបាយការណ៍លទ្ធផល ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ សមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មានសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ ចំនួន៨សវនដ្ឋាន៖ ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងនាយកដ្ឋានគ្រប់គ្រងបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមប្រព័ន្ធព័ត៌មានវិទ្យា

- ចុះធ្វើសវនកម្ម ព្រមទាំងរៀបចំរបាយការណ៍បញ្ចប់សវនកម្មចំនួន ៦សវនដ្ឋានៈ រាជធានីភ្នំពេញ ខេត្តរតនគិរី ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន និងខេត្តកំពត រាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រី, អាជ្ញាធរសវនកម្មជាតិ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សវនដ្ឋាន និងរក្សាទុកនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ចុះតាមដានការអនុវត្តអនុសាសន៍សវនកម្ម ព្រមទាំងរៀបចំរបាយការណ៍លទ្ធផលចំនួន៨សវនដ្ឋានៈ ខេត្តកំពង់ឆ្នាំង ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តកោះកុង ខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តកណ្តាល និងខេត្តបន្ទាយមានជ័យ
- បញ្ជូនឯកសារជូនដំណឹង បង្វែរថវិកា និងសាលាកបត្របង់សំណៃសចំណាយ ប្រចាំឆ្នាំ២០២០-២០២២ ទៅអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ។

## ខ.៥. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត

អនុវត្តតាមសេចក្តីណែនាំលេខ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ក្រសួងមុខងារសាធារណៈ បានចាត់តាំងថ្នាក់ដឹកនាំមួយរូប និងមន្ត្រីថ្នាក់អគ្គនាយករងចំនួន១រូប ឱ្យចូលរួមជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលនៅតាមបណ្តារាជធានី ខេត្ត ចំនួន២៤ ទូទាំងប្រទេស។ ដោយឡែកក្រោយពេលទទួលបានសេចក្តីសម្រេចចាត់តាំងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ តាមរយៈលិខិតលេខ ២០៩ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងនាមប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ បានសម្រេចនូវការងារមួយចំនួនដូចខាងក្រោមៈ

- បានចុះប្រកាសក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ និងប្រកាសសេចក្តីសម្រេចស្តីពីការបែងចែកសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុកទាំង៩ នៃខេត្តកំពង់ស្ពឺ ដែលក្នុងនោះក៏បានចាត់តាំងថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងមុខងារសាធារណៈ ចូលរួមជាសមាជិក និងប្រធានក្រុមការងាររាជរដ្ឋាភិបាល តាមបណ្តាក្រុង ស្រុកទាំង៩ ផងដែរ។
- បានចេញលិខិតជម្រាបជូនដល់អភិបាលនៃគណៈអភិបាលខេត្ត និងអភិបាលក្រុង ស្រុកទាំង៩នៃខេត្តកំពង់ស្ពឺ ឱ្យជួយជំរុញ និងផ្សព្វផ្សាយដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសាររងហានិភ័យឱ្យចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញឱ្យបានច្រើនបន្ថែមទៀតក្នុងក្របខណ្ឌខេត្តកំពង់ស្ពឺ។
- បានចុះប្រជុំជំរុញអនុវត្តខ្លឹមសារអនុក្រឹត្យលេខ ២៩០ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការផ្ទេរទ្រព្យសម្បត្តិរដ្ឋ និងអនុប្បយោគដី នៅភូមិអន្លង់គង់ ឃុំត្រពាំងគង ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋចំនួន៦០គ្រួសារ អាចធ្វើប័ណ្ណកម្មសិទ្ធិបាន។
- បានចេញសេចក្តីសម្រេចចាត់តាំងក្រុមជនបង្គោលនៃក្រសួងមុខងារសាធារណៈ ដើម្បីទទួលបន្ទុកជួយសម្របសម្រួលធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ បញ្ហាប្រឈម និងសំណូមពរពីតំណាងក្រសួងមុខងារសាធារណៈ ដែលត្រូវបានចាត់តាំងឱ្យចូលរួមជាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត និងធ្វើរបាយការណ៍ស្តីពីការដោះស្រាយឆ្លើយតបបញ្ហាប្រឈមនានានៅមូលដ្ឋាន ដែលពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងមុខងារសាធារណៈ។
- បានចេញសេចក្តីសម្រេចចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានតាមបណ្តាឃុំសង្កាត់ នៃក្រុង ស្រុកទាំង៩ នៃខេត្តកំពង់ស្ពឺបានរួចរាល់។

## គ. បញ្ហាប្រឈម

- ចាប់ពីនីតិកាលទី៧ នៃរដ្ឋសភា ក្រសួងមុខងារសាធារណៈបានឈានចូលដំណាក់កាលថ្មីនៃកិច្ចការកែទម្រង់រដ្ឋបាលសាធារណៈ។ ជាទូទៅ ការអនុវត្តកិច្ចការនេះតែងទទួលបាននូវការរុញច្រានមកវិញ អាស្រ័យដោយកិច្ចការនេះត្រូវកែទម្លាប់និងបែបបទការងារដែលមានជាយូរមក ហើយក៏អាចប៉ះពាល់ដល់ផលប្រយោជន៍បុគ្គលនិងអង្គភាពផងដែរ។

ការជម្នះបញ្ហាប្រឈមនេះទាមទារនិរន្តរភាពនៃការគាំទ្រប្រកបដោយឆន្ទៈមុះមុតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃរាជរដ្ឋាភិបាល
- ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ និងការលើកកម្ពស់គុណភាពសេវាសាធារណៈ បានបន្ថែមសម្ពាធលើតម្រូវការសមត្ថភាពនិងជំនាញរបស់មន្ត្រីរាជការ
- បរិមាណ និងគុណភាពនៃសម្ភារបរិក្ខារព័ត៌មានវិទ្យានិងមិនមែនព័ត៌មានវិទ្យាសម្រាប់ប្រកបកិច្ចការ និងបំពេញភារកិច្ចរបស់មន្ត្រីនៅមានកម្រិត។

## ឃ. ទិសដៅការងារបន្ត

- បន្តសហការជាមួយក្រសួង ស្ថាប័ន រៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលស្របតាមគោលការណ៍ថ្មី និងនិយាមនីតិវិធីប្រតិបត្តិ សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល
- ជំរុញកិច្ចដំណើរការនៃការផ្ទេរបុគ្គលិកអប់រំទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ពង្រឹងសមត្ថភាពឌីជីថលដោយផ្តោតលើការប្រើប្រាស់ប្រព័ន្ធបម្រែបម្រួលស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីរាជការ, ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល(Smart Card), ប្រព័ន្ធ HRMIS និង Payroll ថ្មី
- រៀបចំការពិពណ៌នាមុខតំណែងគ្រប់គ្រង មុខតំណែងវិជ្ជាជីវៈ និងប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- រៀបចំគោលនយោបាយបៀវត្ស ការចំណាយបន្ទុកបុគ្គលិក និងលាភការសម្រាប់មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ
- រៀបចំក្របខណ្ឌការអភិវឌ្ឍសមត្ថភាព ភាពជាអ្នកដឹកនាំសម្រាប់អ្នកគ្រប់គ្រងកម្រិតគ្រប់គ្រងនាយកដ្ឋាន
- សិក្សា និងរៀបចំឯកសារក្រមសីលធម៌សម្រាប់មន្ត្រីរាជការស៊ីវិល
- សិក្សា និងពិនិត្យឡើងវិញលើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការវាយតម្លៃនិងទទួលស្គាល់អ្នកដឹកនាំគំរូក្នុងរដ្ឋបាលសាធារណៈ
- ផ្តល់ការគាំទ្រដល់ការអនុវត្តការងារជំរុញបរិវត្តកម្ម នវានុវត្តន៍ និងឧត្តមានុវត្តនៃការផ្តល់សេវាសាធារណៈ
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យមុខងារសាធារណៈ
- ធ្វើអធិការកិច្ចមុខងារសាធារណៈនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ សរុបចំនួន២៧
- ពិនិត្យនិងវាយតម្លៃសេវាសាធារណៈនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ សរុបចំនួន៨
- កសាង និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារអធិការកិច្ចវិស័យមុខងារសាធារណៈ
- រៀបចំនិងដាក់ឱ្យអនុវត្តផែនការសកម្មភាព នៃវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFM) ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ជំរុញការអនុវត្តការចុះកត់ត្រាទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធ SARMIS និងពង្រឹងការទទួលខុសត្រូវលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បន្តជំរុញនិងលើកកម្ពស់ការងារផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់ក្រសួង
- បន្តនិងពង្រឹងការងាររៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥ (AOP-2025) របស់ក្រសួងមុខងារសាធារណៈ និងលើកកម្ពស់ការតាមដានពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពរបស់អង្គភាព
- ជំរុញនិងពង្រឹងការអនុវត្តភារកិច្ចប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវរបស់អង្គភាពក្រោមឱវាទក្រសួងមុខងារសាធារណៈ

## ខ. សេចក្តីសន្និដ្ឋាន

នៅក្នុងឆ្នាំ២០២៣ ក្រសួងមុខងារសាធារណៈ បានដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ ព្រមទាំងការងារកែទម្រង់រដ្ឋបាលសាធារណៈ សម្រេចបាននូវសមិទ្ធផលសំខាន់ៗ ជាច្រើនរួមមាន ការរៀបចំ និងកែលម្អរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ការពង្រឹងការគ្រប់គ្រង ការវិវឌ្ឍអាជីពរបស់មន្ត្រីរាជការ និងការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ការកែលម្អការផ្តល់សេវាសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ដើម្បីបង្កើនប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងរបបសន្តិសុខសង្គម ព្រមទាំងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា។ ជាមួយគ្នានេះ ក្រសួងមុខងារសាធារណៈក៏បានដឹកនាំការកែទម្រង់រដ្ឋបាលសាធារណៈ និងអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈយ៉ាងសកម្ម និងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ហើយជាជំហានៗទាក់ទាញបានការជឿទុកចិត្តនិងការពេញចិត្តរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ។

ផ្អែកលើទិសដៅការងារដែលបានកំណត់ ក្រសួងមុខងារសាធារណៈ នឹងប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងការគ្រប់គ្រងវិស័យមុខងារសាធារណៈ និងការកែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍថ្មីៗនៃសង្គមជាតិ៕

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

# ឧបសម្ព័ន្ធ ក
# ក្រុមរូបភាព សកម្មភាពថ្នាក់ដឹកនាំ
# នៃរបាយការណ៍ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣
# និងលើកទិសដៅឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងមុខងារសាធារណៈ ប្រារព្ធបើកសន្និបាតបូកសរុបសមទ្ធិផលការងារ៥ឆ្នាំ (២០១៨-២០២២ ) និង លើកទិសដៅការងារបន្ត នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅសាលាភូមិន្ទរដ្ឋបាល




លើកទិសដៅបន្តរបស់ក្រសួងមុខងារសាធារណៈ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ នៅសាលាភូមិន្ទរដ្ឋបាល






ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានជួបសម្តែងការគួរសមជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី
ព្រុំ សុខា ដើម្បីសំណេះសំណាល និងជម្រាបលា ខណៈដែលឯកឧត្តមទេសរដ្ឋមន្ត្រីត្រូវទទួលភារកិច្ចថ្មី
នាព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមុខងារសាធារណៈ





ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ
និងមន្ត្រីរាជការ ក្រសួងមុខងារសាធារណៈ ទូទាំងប្រទេស ដើម្បីបើកទំព័រការងារថ្មី
នាព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣








ប្រសាសន៍ ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈថ្លែងក្នុងពិធីសំណេះសំណាលជាមួយ
ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃសាលាភូមិន្ទរដ្ឋបាល នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣




កិច្ចប្រជុំស្តីពីបច្ចុប្បន្នភាពស្ថានភាពការងារ និងទិសដៅបន្តរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង
ដឹកនាំដោយ ឯកឧត្តម សុខ សប្បាយណា រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ
នាព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ នៅបន្ទប់ប្រជុំទីស្តីការក្រសួងមុខងារសាធារណៈ





ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានទទួលជួបសំណេះសំណាល និងសម្តែងការគួរសមពីសំណាក់ឯកឧត្តម Justin Kevin Whyatt ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជា នាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមុខងារសាធារណៈ





ឯកឧត្តមរដ្ឋមន្ត្រី ហ៊ុន ម៉ានី បានទទួលជួបលោកជំទាវ Ülkü Kocaefe ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋតួកគី ប្រចាំព្រះរាជាណាចក្រកម្ពុជា
នាព្រឹកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមុខងារសាធារណៈ





ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ អញ្ជើញចូលរួមពិធីកាន់បិណ្ឌវេនទី៣ រួមគ្នា នៅវត្តអង្គសេរីសោភា ហៅវត្តអង្គតាម៉ិញ ថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣





ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានអញ្ជើញដឹកនាំគណៈប្រតិភូក្រសួង ថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" គម្រប់ខួប ១១ឆ្នាំ នៃការយាងសោយទីវង្គតរបស់ព្រះអង្គ នៅមណ្ឌលតម្កល់ព្រះបរមរូប ខាងកើតវិមានឯករាជ្យ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣





ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានអញ្ជើញដឹកនាំប្រជុំដើម្បីផ្សព្វផ្សាយការងារបន្តឆ្ពោះទៅមុខ នៅសាលាភូមិន្ទរដ្ឋបាល រសៀលថ្ងៃព្រហស្បតិ៍ ទី១៩ ខែតុលា ឆ្នាំ២០២៣





នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តមរដ្ឋមន្ត្រី ហ៊ុន ម៉ានី បានទទួលជួបសំណេះសំណាល និងពិភាក្សាការងារជាមួយឯកឧត្តម Park Jung Wook ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងសហការីមកពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ( KOICA ) ប្រចាំកម្ពុជា






ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានទទួលជួបឯកឧត្តម Martin Vavra ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា តបតាមការស្នើរបស់ស្ថានទូតឆែក នារសៀលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមុខងារសាធារណៈ






មន្ទីរមុខងារសាធារណៈទូទាំងប្រទេស ជួបជុំគ្នាដើម្បីចែករំលែកលទ្ធផល និងពិសោធន៍ការងារ ព្រមទាំងទទួលផែនការ ការងារឆ្ពោះទៅមុខ ដឹកនាំដោយ ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ នៅព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣នេះ នៅសាលាភូមិន្ទរដ្ឋបាល





ពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី «ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍»បានប្រព្រឹត្តិទៅក្រោមអធិបតីភាពរបស់ ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅសាលាភូមិន្ទរដ្ឋបាល កាលពីព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣





ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាលបាន អញ្ជើញជាអធិបតីក្នុង «ពិធីបិទវគ្គបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១ និងបើកវគ្គបណ្តុះបណ្តាល តម្រង់ទិសដំបូងមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌថ្មី ឆ្នាំ២០២៣ នៃក្រសួងអប់រំ យុវជន និងកីឡា″ នៅសិក្សា សាលាភូមិន្ទរដ្ឋបាល





ឯកឧត្តម ហ៊ុន ម៉ានី អញ្ជើញជាអធិបតីបើកសិក្ខាសាលាស្តីពី៖ «ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំ ប្រកបដោយបរិវត្តកម្ម សម្រាប់មន្ត្រីជាន់ខ្ពស់នៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសទីម័រខាងកើត» (សៀមរាប)៖ នាព្រឹកថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣






ក្រសួងមុខងារសាធារណៈ អនុញ្ញាតឱ្យនិស្សិតសាកលវិទ្យាល័យអាស៊ីអឺរ៉ុប ធ្វើទស្សនកិច្ចសិក្សានៅ ក្រសួងមុខងារសាធារណៈ នាព្រឹកថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣





ឯកឧត្តមរដ្ឋមន្ត្រី ហ៊ុន ម៉ានី អញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសចូលកាន់មុខតំណែងថ្នាក់ដឹកនាំ នៃក្រសួងមុខងារសាធារណៈ នៅសាលាភូមិន្ទរដ្ឋបាល នារសៀលថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣






ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី «ការគ្រប់គ្រងថវិកា ការអនុវត្តថវិកា និង ការរៀបចំ ការអនុវត្ត និងត្រួតពិនិត្យតាមដានថវិកាសមិទ្ធកម្ម» ដែលប្រព្រឹត្តទៅនៅខេត្តព្រះសីហនុ រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣





ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ(គ.វ.ជ.) បានដឹកនាំកិច្ចប្រជុំជាមួយសមាជិកនិងក្រុមការងារបច្ចេកទេស នៃគ.វ.ជ. ដើម្បីពិនិត្យវាយតម្លៃជ្រើសរើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២២-២០២៣ នាព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមុខងារសាធារណៈ





សាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណៈ ចុះអនុស្សរណៈ នៃការយោគយល់ ជាមួយក្រសួងព័ត៌មាន និងសាលាជាតិគយ នៅរសៀលថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសាលសហសិក្សាសាលាភូមិន្ទរដ្ឋបាល





ក្រសួងមុខងារសាធារណៈធ្វើពិធីក្រុងពាលីបើកការដ្ឋានជួសជុល និងកែលម្អបរិវេណទីធ្លាក្រសួងឱ្យកាន់តែល្អប្រសើរ នារសៀលថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣





នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈបានជួបសំដែងការគួរសមជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ នៅទីស្តីការអង្គភាពប្រឆាំងអំពើពុករលួយ





វត្តមានជាលើកដំបូងនៃប្រទីបក្រសួងមុខងារសាធារណៈ
ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៣







ក្រសួងមុខងារសាធារណៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំសន្និសីទសារព័ត៌មាន
ស្តីពី «ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំឆ្នាំ២០២៣» នារសៀលថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣





កិច្ចប្រជុំលើកដំបូងក្នុងអាណត្តិទី៧ នៃរដ្ឋសភា រវាងគណៈកម្មការទី៤ នៃរដ្ឋសភា
និងក្រសួងមុខងារសាធារណៈ នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣



គណៈកម្មការបច្ចេកទេសអន្តរក្រសួង នៃ គ.វ.ជ. បន្តចុះវាយតម្លៃនៅទីតាំងជាក់ស្តែងរបស់បេក្ខភាព មណ្ឌលសុខភាព ពេជចង្វារ នៃខេត្តកំពង់ឆ្នាំង នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣





ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានដឹកនាំកិច្ចប្រជុំលើកដំបូង ដើម្បីជួបផ្ទាល់ជាមួយសមាជិក សមាជិការបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ(គ.ក.ស.) ក៏ដូចជាណែនាំតួនាទីភារកិច្ចនិងតម្រង់ទិសការងារបន្ត នារសៀល ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ នៅសាលាភូមិន្ទរដ្ឋបាល






ឯកឧត្តមរដ្ឋមន្ត្រី ហ៊ុន ម៉ានី និងឯកឧត្តមរដ្ឋមន្ត្រី ឌិត ទីណា អញ្ជើញបើកវិញ្ញាសាប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ





នៅព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីអបអរសាទរខួបលើកទី២៥ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ-ឈ្នះ និងខួប៥ឆ្នាំនៃការកសាងវិមានឈ្នះ-ឈ្នះ





ឯកឧត្តមរដ្ឋមន្ត្រី ហ៊ុន ម៉ានី អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃសុក្រ ទី០៥ ខែមករា ឆ្នាំ២០២៤





បុស្បុករូបសំណាកព្រះគ្រូធម្មាចារ្យ គឹម ប្រែង និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន កាលនៅពីកុមារ ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាព ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅស្ពានពាមទេរ ស្ថិតនៅភូមិតាលុស ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ នាព្រឹកថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤





កិច្ចប្រជុំនិយាមលើកទឹកចិត្ត ដឹកនាំដោយ ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ
ក្រសួងមុខងារសាធារណៈ នៅសាលាភូមិន្ទរដ្ឋបាល កាលពីព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤





ក្រសួងមុខងារសាធារណៈ ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សារៀបចំការប្រឡងប្រជែងជ្រើសរើស
មន្ត្រីរាជការស៊ីវិល ៥ ក្រសួងស្ថាប័នទៀត នៅក្រសួងមុខងារសាធារណៈ
នាព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤





ឯកឧត្តម ហ៊ុន ម៉ានី អញ្ជើញបញ្ចុះខណ្ឌសីមា និងសម្ពោធសមិទ្ធផលនានា នៅវត្តក្រពុំឈូក
ហៅវត្តអន្លង់លិញ ស្ថិតនៅឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤





សិក្ខាសាលាចែករំលែកបទពិសោធនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាព
ផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលឆ្នាំ២០២៣
នៅសាលមហោស្រពនៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០២៤




សម្តេចធិបតី ហ៊ុន ម៉ាណែត អញ្ជើញប្រកាសជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និង
សុខាភិបាល ឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៤
នៅសាលមហោស្រពនៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ នាព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤





នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង
ជាប្រធានគណៈកម្មការប្រឡងប្រជែង បានផ្តល់បទសម្ភាសន៍ដល់អ្នកសារព័ត៌មានស្តីពីការប្រកាសលទ្ធផល
ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើក្នុងក្របខណ្ឌអង្គភាពប្រឆាំងអំពើពុករលួយ
ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថិតក្នុងសាលាភូមិន្ទរដ្ឋបាល




ពិធីដង្ហែពានរង្វាន់ជ័យលាភីលេខ១ អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ទូទាំងប្រទេស ឆ្នាំ២០២៣ ដែលវិស័យអប់រំមាន៣ អង្គភាព៖ សាលាអនុវិទ្យាល័យភ្នំយ៉ាត ខេត្តប៉ៃលិន សាលាបឋមសិក្សាស្វាយជ្រំ ខេត្តស្វាយរៀង និងសាលាបឋមសិក្សាសម្តេចជាស៊ីម ខេត្តបាត់ដំបង និងវិស័យសុខាភិបាលមាន១អង្គភាព៖ មណ្ឌលសុខភាពសំរោង ខេត្តពោធិ៍សាត់











ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី អញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងសម្ពោធសមិទ្ធផលនានា នៅវត្តវិហារខ្ពស់ ខេត្តកំពង់ស្ពឺ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤





កិច្ចប្រជុំត្រួតពិនិត្យការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ ដឹកនាំដោយ ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ នៅសាលាភូមិន្ទរដ្ឋបាល ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤





ក្រសួងមុខងារសាធារណៈ ប្រជុំវាយតម្លៃការប្រឡងប្រជែងជ្រើសរើសមន្ត្រី ៣ ក្រសួង-ស្ថាប័ន មានអង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលទើបតែបញ្ចប់កាលពីពេលថ្មីៗនេះ ដឹកនាំដោយ ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ នៅសាលាភូមិន្ទរដ្ឋបាល នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤






ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី អញ្ជើញបើកវគ្គបណ្តុះបណ្តាលស្តីពី«ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ជំនាន់ទី៦» នៅសាលាភូមិន្ទរដ្ឋបាល នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤






ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានាក្នុងវត្តអង្គលំទង ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២៤







ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE


ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+855) 23 866 501
info@mcs.gov.kh
www.mcs.gov.kh
civilservicecambodia
civilservicecambodia
Ministry of Civil Service
Ministry of Civil Service
Ministry of Civil Service


សូមស្កេន QR code ដើម្បីតភ្ជាប់ទៅ
បណ្តាញសង្គមរបស់ក្រសួងមុខងារសាធារណៈ